សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

CAMBODIAN WATER SUPPLY ASSOCIATION


# របាយការណ៍ប្រចាំឆ្នាំ ២០២២


017 799-337 | 070 799-337 | 097 7 179-943

info@cwa.org.kh

អាសយដ្ឋាន: មជ្ឈមណ្ឌលភ្នំពេញ អគារ F ជាន់ទី២ បន្ទប់លេខ ២៦៩
វិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

# មាតិកា

១. អំពីសមាគម ..... 1
១.១ សេចក្តីផ្តើម ..... 1
១.២ ទស្សនវិស័យ និងបេសកកម្ម ..... 2
១.២.១ ទស្សនវិស័យ ..... 2
១.២.២ បេសកកម្ម ..... 2
១.៣ គោលដៅយុទ្ធសាស្ត្រ ..... 3
១.៤ សមាសភាពក្រុមប្រឹក្សាភិបាលសមាគម ..... 3
១.៥ បុគ្គលិកសមាគម ..... 4
២. អភិបាលកិច្ច ..... 5
២.១ សន្និបាតប្រចាំឆ្នាំ ២០២១ ..... 5
២.២ សន្និសីទ និងពិព័រណ៍ទឹកកម្ពុជាលើកទី៤ ..... 6
២.៣ លទ្ធផលការងារក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រតិបត្តិ ..... 7
២.៣.១ កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ..... 7
២.៣.២ ការកសាងទំនាក់ទំនងជាមួយក្រសួង ឧវបន ..... 8
២.៣.៣ ការចូលរួមក្នុងសិក្ខាសាលា ..... 9
២.៣.៤ មូលនិធិសម្រាប់មន្ទីរពេទ្យគន្ធបុប្ផា ..... 10
៣. ការងារជាមួយសមាជិក ..... 10
៣.១ អំពីសមាជិកភាព ..... 10
៣.២ កិច្ចប្រជុំតាមតំបន់ ..... 11
៤. ភាពជាតំណាងឱ្យសមាជិក ..... 11
៤.១ កិច្ចសហការថ្នាក់ជាតិ ..... 11
៤.១.១ កិច្ចប្រជុំជាមួយអគ្គនាយកដ្ឋានទឹកស្អាត ..... 11
៤.១.២ ការចុះអនុស្សារណៈនៃការយោគយល់គ្នា ..... 12

៤.២ កិច្ចប្រជុំដោះស្រាយបញ្ហាសមាជិក.......... 14

៤.៣ កិច្ចសហការអន្តរជាតិ .......... 15

៤.៣.១ កិច្ចសហការជាមួយសមាគមទឹកក្រៅប្រទេសទីក្រុងគីតាឃ្យូស៊ុ (KOWBA) .......... 15

៤.៣.២ កិច្ចប្រជុំសហការជាមួយសមាគមទឹកអូស្ត្រាលី.......... 16

៤.៣.៣ ដំណើរទស្សនកិច្ចសិក្សា .......... 17

៤.៤ ទស្សនកិច្ចសិក្សាក្រៅប្រទេស .......... 18

៤.៤.១ កិច្ចប្រជុំកំពូលស្តីពី«បច្ចេកវិទ្យា និងនវានុវត្តន៍វិស័យទឹកស្អាតពិភពលោកឆ្នាំ២០២២» នៅទីក្រុងឡុងដ៍ ចក្រភពអង់គ្លេស ពីថ្ងៃទី១៩-២៥ ខែកុម្ភៈ ឆ្នាំ២០២២ .......... 18

៤.៤.២ វេទិកាទឹកពិភពលោក World Water Forum .......... 18

៤.៤.៣ ទស្សនកិច្ចសិក្សាទៅប្រទេម៉ាឡេស៊ី.......... 19

៥. កម្មវិធីកសាងសមត្ថភាពសមាជិក.......... 19

៥.១ វគ្គបណ្តុះបណ្តាល.......... 19

៥.១.១ វគ្គបណ្តុះបណ្តាលស្តីពីពន្ធដារ .......... 19

៥.១.២ វគ្គបណ្តុះបណ្តាលស្តីពីការសន្សំសំចៃថាមពលអគ្គិសនី .......... 20

៦. ការងារសហការជាមួយដៃគូអភិវឌ្ឍន៍ .......... 21

៦.១ គម្រោងគាំទ្រហិរញ្ញប្បទានលើការងារទឹកស្អាត និងអនាម័យ(WASH-FIN).......... 21

៦.១.១ កិច្ចប្រជុំពិគ្រោះយោបល់ រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត.......... 21

៦.១.២ វគ្គបណ្តុះបណ្តាល .......... 22

៦.១.៣ ការបិទបញ្ចប់ និងការផ្ទេរបញ្ចាំងគម្រោង.......... 22

៦.១.៤ ដំណើរទស្សនកិច្ចសិក្សា កម្ពុជា-ម៉ូហ្សាំប៊ីក .......... 23

៦.១.៥ ការសិក្សាអំពីអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតឯកជននៅប្រទេសកម្ពុជា.......... 24

៦.២ គម្រោងការពង្រឹងមូលដ្ឋានគ្រឹះសម្រាប់សន្តិសុខទឹក នៅកម្រិតស្រុក ក្នុងប្រទេសកម្ពុជា (WaterAid) 24

៦.២.១ សិក្ខាសាលារៀបចំផែនការគ្រប់គ្រងធនធានទឹកប្រកបដោយបរិយាប័ន្ន.......... 24

៦.២.២ វគ្គបណ្តុះបណ្តាលស្តីពី«កិច្ចប្រជុំផ្សព្វផ្សាយតាមខ្នងផ្ទះអំពីសារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាត» ...... 24
៦.២.៣ រៀបចំកិច្ចប្រជុំផ្សព្វផ្សាយតាមសហគមន៍ «សារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាត» ...... 25
៦.២.៤ វគ្គបណ្តុះបណ្តាលស្តីពី «បច្ចេកទេសនៃការផលិតទឹកស្អាត និងការតេស្តគុណភាពទឹកស្អាត» និង « វិធានការកាត់បន្ថយផលប៉ះពាល់ពីគ្រោះរាំងស្ងួត និងទឹកជំនន់សម្រាប់ការផ្តល់ សេវាផ្គត់ផ្គង់ទឹកស្អាត» .. 25
៦.២.៥ វគ្គបង្វឹកស្តីពី «ការតេស្តគុណភាពទឹកស្អាត» ...... 25
៦.២.៦ សិក្ខាសាលាតម្រង់ទិសស្តីពី «ប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត» និង «ការប្រកួតប្រជែង វិស័យឯកជនគំរូក្នុងការផ្តល់សេវាទឹកស្អាតនៅក្នុងសហគមន៍» ...... 25
៦.៣ គម្រោងការពង្រឹងគណនេយ្យភាពរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតដើម្បីលើកកម្ពស់សេវាកម្មទឹកស្អាត ( WaterAid ) ...... 26
៦.៣.១ វគ្គបណ្តុះបណ្តាល ...... 26
៦.៣.២ សិក្ខាសាលាតម្រង់ទិសស្តីពី«ប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត» ...... 26
៦.៣.៣ វគ្គបង្វឹក ...... 27
៦.៣.៤ កិច្ចប្រជុំថ្នាក់ឃុំ ...... 28
៦.៣.៥ កិច្ចប្រជុំកិច្ចប្រជុំពិគ្រោះយោបល់លើការអនុវត្តគម្រោង ...... 28
៦.៣.៦ កិច្ចប្រជុំឆ្លុះបញ្ចាំង ...... 29
៦.៣.៧ ជួយឧបត្ថម្ភធនតំណភ្ជាប់បណ្តាញទឹកស្អាតជូនគ្រួសារក្រីក្រ ...... 29
៦.៣.៨ ទស្សកិច្ចសិក្សារបស់ម្ចាស់ជំនួយ WaterAid ...... 29
៦.៤ បង្កើនការទទួលសេវាទឹកស្អាត និងអនាម័យដែលធន់នឹងអាកាសធាតុសម្រាប់ជនងាយរងគ្រោះនៅតាមសហគមន៍ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីផ្នែកក្នុងវិស័យទឹកស្អាត និងអនាម័យប្រកបដោយបរិយាប័ន្ន ( WaterAid ) ...... 30
៦.៤.១ សិក្ខាសាលាផ្សព្វផ្សាយគម្រោង ...... 30
៦.៤.២ វគ្គបង្វឹក ...... 30
៦.៤.៣ ទិន្នន័យគ្រួសារក្រីក្រ ...... 31
៦.៤.៤ វគ្គបណ្តុះបណ្តាល ...... 31
៦.៤.៥ ការរៀបចំកិច្ចប្រជុំថ្នាក់ក្រោមជាតិ និងកិច្ចប្រជុំឆ្លុះបញ្ចាំងគម្រោង ...... 33

៦.៤.៦ ជំនួយឧបត្ថម្ភធនលើតំណភ្ជាប់បណ្តាញទឹកស្អាតជូនគ្រួសារក្រីក្រ ...................................... 34
៦.៤.៧ ផលិតសម្ភារៈផ្សព្វផ្សាយរូបភាពផ្ទាំងធំអំពីភាពធន់នឹងការប្រែប្រួលអាកាសធាតុ...................... 34
៦.៥ បង្កើននូវភាពធន់ នឹងអាកាសធាតុសម្រាប់ការផ្គត់ផ្គង់ទឹកស្អាត ដល់ឃុំដែលមានហានិភ័យខ្ពស់ប្រឈមទៅនឹងបម្រែបម្រួលអាកាសធាតុ ( UNICEF ) ........................................................................ 35
៦.៥.១ វឌ្ឍនភាពរបស់គម្រោងលើការពង្រីកបណ្តាញ............................................................... 35
៦.៥.២ វឌ្ឍនភាពរបស់គម្រោងលើការកែលម្អប្រភពទឹក .......................................................... 35
៦.៥.៣ វឌ្ឍនភាពរបស់គម្រោងលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត ................................. 35
៦.៥.៤ វឌ្ឍនភាពរបស់គម្រោងលើការចែករំលែកចំណេះដឹង និងការកសាងសមត្ថភាព ...................... 35
៦.៥.៦ សកម្មភាពចុះត្រួតពិនិត្យ និងតាមដានគម្រោង............................................................. 36
៦.៦ គម្រោងសម្ព័ន្ធភាពដើម្បីអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌ ( Aide et Action ) ............................................................................................................. 38
៦.៦.១ សិក្ខាសាលាផ្សព្វផ្សាយគម្រផងថ្នាក់ខេត្ត..................................................................... 38
៦.៦.២ សិក្ខាសាលាផ្សព្វផ្សាយគម្រផងថ្នាក់ស្រុក.................................................................... 38
៦.៦.៣ ការចុះប្រមូលទិន្នន័យ ............................................................................................ 39
៦.៦.៤ ការសិក្សាសមិទ្ធិលទ្ធភាព......................................................................................... 39
៦.៧. គម្រោងឧបត្ថម្ភធនលើថ្លៃភ្ជាប់ទឹកជូនគ្រួសារក្រីក្រ ( EMW ) ............................................. 40
៦.៧.១ ការឧបត្ថម្ភធនលើថ្លៃភ្ជាប់ទឹកជូនគ្រួសារក្រីក្រ ............................................................ 40
៦.៧.២ ការផ្តល់រង្វាន់លើកទឹកចិត្តសម្រាប់ប្រតិបត្តិករឆ្នើម ........................................................ 41
៦.៨ គម្រោងសិក្សារៀបចំព័ត៌មានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត សម្រាប់រកទុនកម្ចី- Water.org ................ 41
៦.៨.១ កិច្ចប្រជុំពិភាក្សាអំពីការប្រមូលទិន្នន័យ......................................................................... 41
៦.៨.២ កិច្ចប្រជុំពិភាក្សាអំពីការប្រមូលទិន្នន័យ ........................................................................ 42
៦.៩ កម្មវិធីវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ( 3i ) ............................................................. 42

# ១. អំពីសមាគម

## ១.១ សេចក្តីផ្តើម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃជាឯកជន មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។ សមាគមបម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។

សមាគមបង្កើតឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយក្រុមអ្នកផ្គត់ផ្គង់ទឹកស្អាតឯកជនមួយក្រុមមានគ្នាប្រមាណជា ២០នាក់ ក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ របស់គម្រោង អេម អេស អេម អ៊ី(MSME) នៃទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ(USAID) និងបានចុះបញ្ជីសមាគមជាផ្លូវការនៅក្រសួងមហាផ្ទៃតាមសេចក្តីជូនដំណឹងលេខៈ ១០៧៧ សជណ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១២។ ក្រសួងមហាផ្ទៃចេញសេចក្តីប្រកាសលេខៈ ២៩០១ ប្រក ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១ សម្រេចចុះឈ្មោះសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ឡើងវិញក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គល មានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលស្ថិតនៅអគារ F ជាន់ទី២ បន្ទប់លេខ ២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សមាគមបង្កើតឡើងក្នុងគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

ក្នុងឆ្នាំ២០២២ សមាគមមានសមាសភាពក្រុមប្រឹក្សាភិបាលចំនួន ៩រូប(ស្រី ១រូប) ដែលមានរចនាសម្ព័ន្ធ៖ ប្រធាន ១រូប អនុប្រធាន ១រូប ហេរញ្ញិក ១រូប និងសមាជិកចំនួន ៦រូប។ សមាគមមានបុគ្គលិកសរុបចំនួន ១០រូប(ស្រី ៤រូប) និងមានសមាជិកសរុបចំនួន ៣២០ស្ថានីយ/ក្រុមហ៊ុន ដែលក្នុងនោះមាន២៨៥ស្ថានីយ បាននឹងកំពុងប្រតិបត្តិការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋនៅក្នុង ២៣រាជធានី/ខេត្ត/ក្រុង នៃព្រះរាជាណាចក្រកម្ពុជា។

## ចំណូលចំណាយរបស់សមាគមប្រចាំឆ្នាំ២០២២







**ចំណូលសរុបប្រចាំឆ្នាំ២០២២**

- ចំណូលពីដៃគូអភិវឌ្ឍន៍៖ ៦៧៤,៧២៧ដុល្លារ (៨៦%)
- ចំណូលពីភាគទានសមាជិកភាព៖ ៦០,៤៨៥ដុល្លារ (៨%)
- ចំណូលផ្សេងៗ៖ ៤៥,៨២០ដុល្លារ (៦%)

**ចំណូលសរុប៖ ៧៨១,០៣២ដុល្លារ (១០០%)**

**ចំណាយសរុបប្រចាំឆ្នាំ២០២២**

- ចំណាយលើការងារអភិវឌ្ឍន៍៖ ៤៣៩,០៣៥ដុល្លារ (៦៩%)
- ចំណាយលើបុគ្គលិក៖ ១៦០,៤៤៣ដុល្លារ (២៥%)
- ចំណាយលើកិច្ចប្រជុំរវាងបុគ្គលិក និងក្រុមប្រឹក្សាភិបាល និងរដ្ឋបាល៖ ៣៥,៤២៩ដុល្លារ (៦%)

**ចំណាយសរុប៖ ៦៣៤,៩០៧ដុល្លារ (១០០%)**

**សមតុល្យយោងសរុបទៅឆ្នាំបន្ទាប់៖ ១៤៦,១២៥ដុល្លារ**

# ១.២ ទស្សនវិស័យ និងបេសកកម្ម

## ១.២.១ ទស្សនវិស័យ

ទស្សនៈវិស័យរបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា
គឺចង់ឃើញប្រជាពលរដ្ឋកម្ពុជានៅគ្រប់តំបន់ក្នុងព្រះរាជាណាចក្រកម្ពុជាទទួលបានសេវាទឹកស្អាត និងអនាម័យដែលមានគុណភាពស្របតាមស្តង់ដាថ្នាក់ជាតិ។

## ១.២.២ បេសកកម្ម

បេសកកម្មរបស់សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា មានបីគឺ៖

១. គាំទ្រ និងលើកកម្ពស់ការជួយគ្នាទៅវិញទៅមករវាងអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា

២. បង្កើនចំណេះដឹង បច្ចេកទេសស្របតាមស្តង់ដាទឹកស្អាតថ្នាក់ជាតិ និង

៣. ជំរុញឱ្យមាននិរន្តរភាព និងការពង្រីកសេវាកម្មផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា។

## ១.៣ គោលដៅយុទ្ធសាស្ត្រ

ក្នុងឆ្នាំ២០២២ សមាគមបន្តអនុវត្តតាមផែនការយុទ្ធសាស្ត្រ ២០២០ -២០២៤។

- ❖ ការពារ និងពង្រឹងសមត្ថភាពសមាជិករបស់ខ្លួន
- ❖ ធ្វើឱ្យមាននិរន្តរភាពហិរញ្ញវត្ថុរបស់សមាគម
- ❖ ចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ការប្រើប្រាស់ទឹកស្អាត។

## ១.៤ សមាសភាពក្រុមប្រឹក្សាភិបាលសមាគម

ក្រុមប្រឹក្សាភិបាលអាណត្តិទី៣ សម្រាប់ឆ្នាំ២០២០-២០២៣ មានចំនួន ៩នាក់ (ស្រី១នាក់) ដូចមានរាយនាមក្នុងអង្គការលេខខាងក្រោម៖



## ១.៥ បុគ្គលិកសមាគម

នៅឆ្នាំ២០២២នេះ សមាគមមានបុគ្គលិកចំនួន ១០នាក់ (ស្រី ៤នាក់) ដែលមានឈ្មោះ និងតួនាទីដូចខាងក្រោម៖



លោក លឹម មិញ
នាយកប្រតិបត្តិ
minh.lim@cwa.org.kh



លោក ហេង ពិសិដ្ឋ
ប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ
piseth.heng@cwa.org.kh



លោក រៀល វីរ៉ា
ប្រធានកម្មវិធី
vira.riel@cwa.org.kh



អ្នកស្រី តូច សុគន្ធា
អ្នកសម្របសម្រួលកម្មវិធី
sokunthea.toch@cwa.org.kh



លោក ជ្រិន ផាត់
វិស្វករជំនាញជាន់ខ្ពស់ទឹកស្អាត
phat.chrin@cwa.org.kh



កញ្ញា ខាត់ ដាវី
មន្ត្រីបច្ចេកទេសទឹកស្អាត អនាម័យ និងសម្របសម្រួលសមាជិកភាព
davy.khath@cwa.org.kh



លោក ឯម សារ៉ុម
មន្ត្រីទំនាក់ទំនង
sarom.em@cwa.org.kh



លោក សារ៉ែន ហ៊ិន
ជំនួយការផ្នែកព័ត៌មានវិទ្យា
hin.saraen@cwa.org.kh



លោកស្រី ដួក ម៉ារី
មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ
mary.douk@cwa.org.kh



កញ្ញា ហេង រចនា
វិស្វករទឹកស្អាត
rachana.heng@cwa.org.kh

# ២. អភិបាលកិច្ច

## ២.១ សន្និបាតប្រចាំឆ្នាំ ២០២១

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជាបានរៀបចំសន្និបាតលើកទី១០ ប្រចាំឆ្នាំ២០២១ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ ពីម៉ោង១៣:០០ ដល់ម៉ោង ២១:០០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **អ៊ុំ សុថា** រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧវបន) និងជាតំណាងដ៏ខ្ពស់របស់ **ឯកឧត្តមកិត្តិសេដ្ឋា បណ្ឌិត ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងឧវបន ឯកឧត្តម **តន់ សុខដា** អគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាត ព្រមទាំងមន្ត្រីអមដំណើរ ឯកឧត្តម **ស្រ៊ិន ពុទ្ធី** ទីប្រឹក្សាក្រសួង និងជាប្រធាននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ អង្គការដៃគូ តំណាងទូត និងសមាជិករបស់សមាគម សរុបចំនួន ២៧០នាក់ ស្ត្រីចំនួន ៥៨នាក់។



*រូបភាពទី១៖ សុន្ទរកថាបើកអង្គសន្និបាតសមាគមដោយ ឯកឧត្តម អ៊ុំ សុថា*



*រូបភាពទី២៖ រូបភាពអនុស្សាវរីយ៍នៅថ្ងៃសន្និបាតសមាគម*

អង្គសន្និបាតលើកទី១០ ប្រចាំឆ្នាំ២០២១ ទទួលបានការចូលរួមឧបត្ថម្ភដោយៈ

*តារាងទី១ៈ បញ្ជីឈ្មោះក្រុមហ៊ុនដែលឧបត្ថម្ភសន្និបាត*

| ល.រ | បញ្ជីឈ្មោះក្រុមហ៊ុនដែលឧបត្ថម្ភសន្និបាត | សមាជិក / ដៃគូ |
|---|---|---|
| ១ | ក្រុមហ៊ុន ភ្នំពេញប្លាស្ទិច ប្រូដាក់ | សមាជិកសមាគម CWA |
| ២ | ក្រុមហ៊ុន ធីស៊ីយូ ប៉ូលី អេធីប្រាយ | សមាជិកសមាគម CWA |
| ៣ | ក្រុមហ៊ុន ជី អ៊ី អឹម ខូអិលធីឌី | សមាជិកសមាគម CWA |
| ៤ | សហគ្រាស អ៊ី-ផៅវ័រ ស៊ីស៊ីអិល | សមាជិកសមាគម CWA |
| ៥ | សហគ្រាស វ៉ធើរ ផាតនឺរ (ខេមបូឌា) ឯ.ក | សមាជិកសមាគម CWA |
| ៦ | ក្រុមហ៊ុន វ៉ធើម៉ិច ថេកណូឡូជី | សមាជិកសមាគម CWA |
| ៧ | ក្រុមហ៊ុន ខេស៊ីអេអាយ អ៊ិនធើណេសិនណល ខូអបភើរេសិន ឯ.ក | សមាជិកសមាគម CWA |
| ៨ | ក្រុមហ៊ុន ធីនីម៉ិច ខូអេលធីឌី | សមាជិកសមាគម CWA |
| ៩ | ការិយាល័យតំណាង របស់ក្រុមហ៊ុន Fuji Electric Co., Ltd | សមាជិកសមាគម CWA |
| ១០ | អ៊ីឌែមីតស៊ុ សេហ្សុង ម៉ាយក្រូហ្វាយនែន (ខេមបូឌា) | សមាជិកសមាគម CWA |
| ១១ | ក្រុមហ៊ុន Water Tiger Solution | សមាជិកសមាគម CWA |
| ១២ | ធនាគារ Phillip Bank | ដៃគូក្នុងស្រុក |
| ១៣ | ធនាគារ FTB Bank | ដៃគូក្នុងស្រុក |
| ១៤ | ក្រុមហ៊ុន ISEA និង The Stone Family Foundation និង | ដៃគូក្នុងស្រុក |
| ១៥ | ក្រុមហ៊ុន HITACHI Zosen Cooperation | ដៃគូអន្តរជាតិ |
| ១៦ | ក្រុមហ៊ុន Hydro Scada Solution | ដៃគូអន្តរជាតិ |
| ១៧ | សមាគមទឹកអូស្ត្រាលី (AWA) | ដៃគូអន្តរជាតិ |
| ១៨ | សមាគមអាជីវកម្មទឹកបរទេសនៃទីក្រុងKitakyushu (KOWBA) | ដៃគូអន្តរជាតិ |

## ២.២ សន្និសីទ និងពិព័រណ៍ទឹកកម្ពុជាលើកទី៤

ថ្ងៃទី២៩-៣០ ខែវិច្ឆិកា ឆ្នាំ២០២២ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានសហការជាមួយអគ្គនាយកដ្ឋានទឹកស្អាត នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងការរៀបចំ សន្និសីទ និងពិព័រណ៍ទឹកកម្ពុជា លើកទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ស៊ឹម ស៊ីថា** រដ្ឋលេខាធិការ និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមកិត្តិសេដ្ឋា បណ្ឌិត ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងឧ.វ.ប.ន។ សន្និសីទ និងពិព័រណ៍ទឹកកម្ពុជា លើកទី៤ នេះផ្តោតលើប្រធានបទ«***ផ្តល់គុណតម្លៃទឹក កុំរង់ចាំដល់ដំណាក់ចុងក្រោយ ដើម្បីធានានិរន្តរភាពទឹកនាពេលអនាគត***»។ ជាលទ្ធផលមានអ្នកចូលរួមសរុបចំនួន ៦១៥នាក់ ស្ត្រីចំនួន ៣៧៥នាក់។

សន្និសីទ និងពិព័រណ៍ទឹកកម្ពុជា លើកទី៤ នេះទទួលបានការឧបត្ថម្ភពីអង្គការដៃគូ និងក្រុមហ៊ុន ជាតិ និងអន្តរជាតិរួមមាន៖ CAP RED, World Bank, Water.org, WaterAid, UNICEF, Australian Water Association ( AWA ), KOWBA, FTB, Watermech Technology, TEM Trading Co., Ltd, TCU Poly Enterprise, Phnom Penh Plastic product, KCRI International Cooperation Co., Ltd, Stone Family Foundation, GEOCRAFT, Hitachi Zosen Corporation, E-Water, ISEA, Agenda for change, The VF Foundation, Australian Water Partnership, Water Partners ( Cambodia ) Company Limited។




*រូបភាពទី៣៖ ឯកឧត្តម ស៊ឹម ស៊ីថា រដ្ឋលេខាធិការក្រសួង ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ កាត់ខ្សែបូ សន្និសីទ និងពិព័រណ៍ទឹកកម្ពុជា លើកទី៤*

# ២.៣ លទ្ធផលការងារក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រតិបត្តិ

## ២ ១.៣.កិច្ចប្រជុំកក្រុមប្រឹក្សាភិបាល

ក្នុងឆ្នាំ២០២២ សមាគមបានរៀបចំកិច្ចប្រជុំត្រីមាសរបស់ក្រុមប្រឹក្សាភិបាលបានចំនួន ៣ត្រីមាស និងកិច្ចប្រជុំវិសាមញ្ញចំនួន ១ដង៖

- ត្រីមាសទី១៖ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ ផ្ដោតទៅលើ ១. វិសោធនកម្មគោលនយោបាយបុគ្គលិក និងគោលនយោបាយហិរញ្ញវត្ថុ ២. ការសម្រេចរៀបចំសន្និសីទ និងពិព័រណ៍ទឹកកម្ពុជាលើកទី៤។
- ត្រីមាសទី២៖ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២២ បានពិភាក្សា ១. លើការបន្តអនុស្សារណៈយោគយល់គ្នាជាមួយអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧស្សាហកម្ម សម្រាប់រយៈពេល៥ឆ្នាំ ២.ការកំណត់លើប្រាក់សមាជិកភាពប្រចាំឆ្នាំ ៣. ការត្រួតពិនិត្យគុណភាពទឹករបស់សមាជិក។

❖ កិច្ចប្រជុំវិសាមញ្ញ៖ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ តាមប្រព័ន្ធអនឡាញ (ZOOM-CALL) និងបានសម្រេចដូចខាងក្រោម៖
១.សម្រេចរៀបចំសន្និសីទ និងការតាំងពិព័រណ៍ទឹក នៅចុងខែវិច្ឆិកា ឆ្នាំ២០២២
២. ការស្នើសុំទស្សនកិច្ចសិក្សារបស់សមាជិក និងសមាគមទៅប្រទេសជប៉ុនតាមរយៈ សមាគមទឹកជប៉ុន (KOWBA)។



*រូបភាពទី៤៖ កិច្ចប្រជុំប្រចាំត្រីមាសរបស់ក្រុមប្រឹក្សាភិបាលនៅការិយាល័យ*

❖ ត្រីមាសទី៣៖ ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២២ បានពិភាក្សា ១. អនុញ្ញាតឲ្យសមាគមរៀបចំវគ្គតម្រង់ទិសលើប្រកាសអនុញ្ញាត២០ឆ្នាំ របៀបកត់ត្រាគណនេយ្យ របៀបធ្វើទីផ្សារជូនដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ២. ដោះស្រាយបញ្ហាសមាជិកនៅស្ពានីយទន្លេបិទ។

## ២.៣.២ ការកសាងទំនាក់ទំនងជាមួយក្រសួង ឧវបន

ឆ្នាំ២០២២ ក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំសមាគមបានចូលជួបសម្តែងការគួរសមចំពោះថ្នាក់ដឹកនាំក្រសួងចំនួន ២លើក ក្នុងន័យពង្រឹងកិច្ចសហប្រតិបត្តិការរវាងសមាគម និងក្រសួង ដូចខាងក្រោម៖

❖ ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ ក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំសមាគម មានកិត្តិយសបានចូលជួបសម្តែងការគួរសម និងគោរពជូនពរ **ឯកឧត្តមកិត្តិសេដ្ឋា បណ្ឌិត ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងឧវបន និង **ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦។



*រូបភាពទី៥៖ ការចូលជួបសម្តែងការគួរសម និងថតរូបអនុស្សាវរីយ៍*

❖ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ ក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំសមាគម មានកិត្តិយសបានចូលជួបសម្តែងការគួរសម និងគោរពជូនពរដល់ **ឯកឧត្តមកិត្តិសេដ្ឋា បណ្ឌិត ចម ប្រសិទ្ធ** ទេសរដ្ឋមន្រ្តី រដ្ឋមន្រ្តី ក្រសួងឧស្សាហកម្ម ក្នុងពិធីបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ។ ឆ្លៀតក្នុងឱកាសនោះដែរ ក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិសមាគម ក៏បានចូលជួបដើម្បីសម្តែងការគួរសម និងគោរពជូនពរក្នុងឱកាសបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរជូនដល់ **ឯកឧត្តម អ៊ឹុំ សុថា** រដ្ឋលេខាធិការ និង **ឯកឧត្តម តន់ សុខជា** អគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាត ផងដែរ។



*រូបភាពទី៦៖ ការថតរូបអនុស្សាវរីយ៍ក្នុងឱកាសជួបសម្តែងការគួរសម និងគោរពជូនពរថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម*

## ២.៣.៣ ការចូលរួមក្នុងសិក្ខាសាលា

ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២ **លោក ឡេង ខៀវ** បានដឹកនាំក្រុមប្រឹក្សាភិបាល បុគ្គលិក និងសមាជិកសមាគម ចូលរួមសិក្ខាសាលាស្តីពី «**បច្ចេកវិទ្យាទឹកស្អាត និងទឹកកខ្វក់ ក្នុងកិច្ចសហការរវាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាមួយក្រុមហ៊ុន ION EXCHANGE**» នៅសណ្ឋាគារកាំបូឌីយ៉ាណា។



*រូបភាពទី៧៖ រូបថតអនុស្សាវរីយ៍ក្រោយបញ្ចប់វគ្គសិក្ខាសាលា*

### ២.៣.៤ មូលនិធិសម្រាប់មន្ទីរពេទ្យគន្ធបុប្ផា

ថ្ងៃទី០៩ ខែសីហា ឆ្នាំ ២០២២ សមាគមបានប្រគល់ប្រាក់ចំនួន **៤,៤២៤.៥៣ ដុល្លារ (បួនពាន់បួនរយម្ភៃបួនដុល្លា និងហាសិបបីសេន)** ដែលជាការបរិច្ចាគរបស់សមាជិកសមាគមជូន មូល-និធិគន្ធបុប្ផាកម្ពុជា តាមរយៈក្រសួងឧ.វ.ប.ន។



*រូបភាពទី៨៖ ការប្រគល់ប្រាក់អង្គាសមូលនិធិគន្ធបុប្ផាកម្ពុជាតាមរយៈអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧវបន*

# ៣. ការងារជាមួយសមាជិក

## ៣.១ អំពីសមាជិកភាព

សមាជិកសមាគមមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាក់ស្តែងសមាជិកសមាគមកើនដល់ ៣២០ ស្ថានីយ/ក្រុមហ៊ុន នៅដំណាច់ឆ្នាំ២០២២ ក្នុងនោះសមាជិកជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសរុបចំនួន ២៨៥ ស្ថានីយ និងសមាជិកជាក្រុមហ៊ុនផ្គត់ផ្គង់លើវិស័យទឹកស្អាត សរុបចំនួន ៣៥ក្រុមហ៊ុន បាននឹងកំពុងប្រតិបត្តិការក្នុង ២៣រាជធានី/ខេត្ត/ក្រុង នៃព្រះរាជាណាចក្រកម្ពុជា។




***ក្រាហ្វិច១៖** ដ្យាក្រាម ចំនួនសមាជិកសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា*

## ៣.២ កិច្ចប្រជុំតាមតំបន់

ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ សមាគមបានរៀបចំកិច្ចប្រជុំថ្នាក់តំបន់ នៅសណ្ឋាគារ ហាន គង់ ដោយមានការចូលរួមសហការឧបត្ថម្ភពីក្រុមហ៊ុន TCU ក្រុមហ៊ុន Phnom Penh Plastic Product ក្រុមហ៊ុន HTS ក្រុមហ៊ុន TEM និងក្រុមហ៊ុន Water Partner ដែលមានអ្នកចូលរួមសរុប ៥៣នាក់ (ស្រី ១០នាក់) ក្នុងនោះមាន ២៦ស្ថានីយ និង ៥ក្រុមហ៊ុន។



*រូបភាពទី៩៖ រូបថតអនុស្សាវរីយ៍ក្នុងកិច្ចប្រជុំតាមតំបន់នៅខេត្តសៀមរាប*

# ៤. ភាពជាតំណាងឱ្យសមាជិក

## ៤.១ កិច្ចសហការថ្នាក់ជាតិ

### ៤.១.១ កិច្ចប្រជុំជាមួយអគ្គនាយកដ្ឋានទឹកស្អាត

ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ សមាគមបានចូលរួមកិច្ចប្រជុំជាមួយអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧស្សាហកម្ម... 



*រូបភាពទី១០៖ កិច្ចប្រជុំជាមួយ អគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាត*

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ ក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិ និងសមាជិកសមាគម បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ និងប្រមូលធាតុចូលលើសេចក្តីព្រាងបឋមបទដ្ឋានគតិយុត្តចំនួន ៤ ក្នុងក្របខណ្ឌគម្រោងកសាងសមត្ថភាពគ្រប់គ្រងវិស័យទឹកស្អាតកម្ពុជា ដែលរៀបចំដោយក្រសួងឧស្សាហកម្ម... 



*រូបភាពទី១១៖ សិក្ខាសាលាពិគ្រោះយោបល់ និងប្រមូលធាតុចូលលើសេចក្តីព្រាងបឋមបទដ្ឋានគតិយុត្តចំនួន៤*

## ៤.១.២ ការចុះអនុស្សរណៈនៃការយោគយល់គ្នា

នៅក្នុងឆ្នាំ ២០២២ សមាគមបានចុះអនុស្សរណៈនៃការយោគយល់គ្នាចំនួន ៣រួមមាន៖

១. ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២ ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា មក.(SME Bank)និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា




ដោយ **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាលសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា និង **លោក លឹម អួន** អគ្គនាយកធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា។

*រូបភាពទី១២៖ រូបថតអនុស្សាវរីយ៍ចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា*

២. ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២២ ពិធីចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នារវាង សមាគមទឹកអូស្ត្រាលី(AWA) និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា(CWA) នៅទីក្រុង Brisbane នៃប្រទេសអូស្ត្រាលីសម្រាប់រយៈពេល ២ឆ្នាំបន្ត ដើម្បីបង្កើនកិច្ចសហការល្អ រវាងសមាគមទាំងពីរ។




*រូបភាពទី១៣៖ ការចុះអនុស្សារណៈនៃការយោគយល់គ្នារវាង CWA និង AWA*

៣. ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ សមាគមបានចុះអនុស្សារណៈនៃការយោគយល់គ្នាជាមួយអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧវបន នៅសណ្ឋាគារ កាំបូឌីយ៉ាណា សម្រាប់រយៈពេល ៥ឆ្នាំ ដើម្បីបន្តកិច្ចសហប្រតិបត្តិការឱ្យកាន់តែមានប្រសិទ្ធភាព។



*រូបភាពទី១៤៖ ការចុះអនុស្សារណៈនៃការយោគយល់គ្នារវាង អគ្គនាយកដ្ឋានទឹកស្អាត និងសមាគម*

## ៤.២ កិច្ចប្រជុំដោះស្រាយបញ្ហាសមាជិក

- ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ សមាគមបានរៀបចំកិច្ចជាមួយ **លោក ឈឹម វាសនា** តំណាងឱ្យ **លោក ផាន់ ម៉ារី** ម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតទន្លេបិទ ដោយមានការចូលរួមពីក្រុមប្រឹក្សាភិបាល ដើម្បីស្វែងរកដំណោះស្រាយចំពោះការមិនចាត់វិធានការតាមផ្លូវច្បាប់របស់អាជ្ញាធរមូលដ្ឋានក្នុងការផ្អាកការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកដែលគ្មានប្រកាសអនុញ្ញាតត្រឹមត្រូវ នៅភូមិសាស្ត្រ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ (ដែលស្ថិតនៅក្នុងប្រកាសអនុញ្ញាតរបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតទន្លេបិទ) តាមលិខិតលេខ ២៣៤៦ ឧវបន.ទស ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ២០២១។



*រូបភាពទី១៥៖ កិច្ចប្រជុំជាមួយក្រុមប្រឹក្សាភិបាល សមាគម និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតទន្លេបិទ*

- ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ សមាគមបានរៀបចំកិច្ចប្រជុំជាមួយ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត មកពីខេត្តកំពង់ឆ្នាំង ចំនួន ៧ស្ថានីយ ដោយមានការចូលរួមពីក្រុមប្រឹក្សាភិបាល ដើម្បីពិភាក្សារកដំណោះស្រាយអំពីការខូចខាតបំពង់ទឹកស្អាតដែលបណ្តាលមកពីការធ្វើផ្លូវលំនៅក្នុងខេត្តកំពង់ឆ្នាំង។ ក្រោមកិច្ចសហការជាមួយអង្គការវ៉ែតធីអេតកម្ពុជា សមាគមបានរៀបចំកិច្ចប្រជុំថ្នាក់ខេត្តដែលមានការចូលរួមពីលោកអភិបាលរងខេត្ត តំណាងមន្ទីរឧវបន តំណាងមន្ទីរអភិវឌ្ឍន៍ជនបទ តំណាងអាជ្ញាធរថ្នាក់ស្រុក/ឃុំ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន។ អង្គប្រជុំបានសម្រេចឱ្យមន្ទីរអភិវឌ្ឍន៍ជនបទ សហការជាមួយមន្ទីរឧវបន មន្ទីរសាធារណការ និងដឹកជញ្ជូន និងមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ខេត្ត ក្នុងការរៀបចំសេចក្តីជូនដំណឹង «ស.ជ.ណ ស្តីពីការប្រើប្រាស់ដីចំណីផ្លូវ និងការកប់បណ្តាញទឹកស្អាត» ដើម្បីស្នើសុំការអនុម័តពីឯកឧត្តមអភិបាលខេត្ត។



*រូបភាពទី១៦៖ កិច្ចប្រជុំជាមួយប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត មកពីខេត្តកំពង់ឆ្នាំង*

# ៤.៣ កិច្ចសហការអន្តរជាតិ

## ៤.៣.១ កិច្ចសហការជាមួយសមាគមទឹកក្រៅប្រទេសទីក្រុងគីតាយូស៊ូ (KOWBA)

សមាគមបានជួយសម្របសម្រួលក្នុងការរៀបចំសិក្ខាសាលាតាមប្រព័ន្ធអនឡាញ ស្តីពីប្រព័ន្ធទឹកស្អាត និងអនាម័យ កម្ពុជា-ជប៉ុន ថ្ងៃទី២៧-២៨ ខែមករា ឆ្នាំ២០២២។



## ៤.៣.២ កិច្ចប្រជុំសហការជាមួយសមាគមទឹកអូស្ត្រាលី

- ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (CWA) បានសហការជាមួយសមាគមទឹកអូស្ត្រាលី (AWA) កម្មវិធីវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i) និងក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាត វីរៃនឈ័រ រៀបចំសិក្ខាសាលាស្តីពី «ការចែករំលែកចំណេះដឹងពីបច្ចេកវិទ្យា Ultra-Filtration និងលទ្ធផលនៃការសាកល្បងប្រើប្រាស់បច្ចេកវិទ្យាសម្អាតទឹក Ultra-Filtration»។



*រូបភាពទី១៧៖ ការចូលរួមវគ្គសិក្ខាសាលានៅការិយាល័យសមាគម*

- ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ ក្រោមកិច្ចសហការរវាងសមាគមទឹកអូស្ត្រាលី កម្មវិធីវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i) និងសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានរៀបចំ «វេទិកាពិភាក្សាស្តីពីគោលនយោបាយទឹក កម្ពុជា អូស្ត្រាលី លើកទី២» នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា។




*រូបភាពទី១៨៖ វេទិកាពិភាក្សាស្តីពីគោលនយោបាយទឹក កម្ពុជា អូស្ត្រាលី លើកទី២*

### ៤.៣.៣ ដំណើរទស្សនកិច្ចសិក្សា

ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២២ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានរៀបចំដំណើរទស្សនកិច្ចជូនគណៈប្រតិភូអូស្ត្រាលី (សមាគមទឹកអូស្ត្រាលី និងមន្ត្រីទូតរបស់អូស្ត្រាលី) ទៅទស្សនកិច្ចនៅស្ថានីយទឹកស្អាតទឹកស្អាតចំនួន ៣ គឺ៖ ១.ស្ថានីយផ្គត់ផ្គង់ទឹកស្អាត កំពង់ចំលង ២.ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ទ្បេងខៀវ ព្រែកអំបិល និង ៣.ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បែកចាន។





*រូបភាពទី១៩៖ ការទស្សនាចង្វាក់ផលិតកម្ម ទឹកស្អាតបែកចាន  រូបភាពទី២០៖ អនុស្សាវរីយ៍នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត កំពង់ចំលង*



*រូបភាពទី២១៖ រូបថតអនុស្សាវរីយ៍នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត ទ្បេងខៀវ ព្រែកអំបិល*

## ៤.៤ ទស្សនកិច្ចសិក្សាក្រៅប្រទេស

### ៤.៤.១ កិច្ចប្រជុំកំពូលស្តីពី«បច្ចេកវិទ្យា និងនវានុវត្តន៍វិស័យទឹកស្អាតពិភពលោកឆ្នាំ ២០២២» នៅទីក្រុងឡុងដ៍ ចក្រភពអង់គ្លេស ពីថ្ងៃទី១៩-២៥ ខែកុម្ភៈ ឆ្នាំ២០២២

តបតាមការអញ្ជើញរបស់ស្ថានទូតចក្រភពអង់គ្លេសប្រចាំនៅទីក្រុងភ្នំពេញ សមាគមបានចូលរួមដំណើរជាមួយគណៈប្រតិភូក្រសួងឧរបន ដឹកនាំដោយ **ឯកឧត្តម ស៊ឹម សុថា** ចូលរួមកិច្ចប្រជុំកំពូលស្តីពី«បច្ចេកវិទ្យា និងនវនុវត្តន៍វិស័យទឹកស្អាតពិភពលោក ឆ្នាំ២០២២ (World Water-Tech Innovation Summit 2022)» នៅទីក្រុងឡុងដ៍ ចក្រភពអង់គ្លេស ពីថ្ងៃទី១៩-២៥ ខែកុម្ភៈ ឆ្នាំ២០២២។



*រូបភាពទី២២៖ កិច្ចប្រជុំជាមួយក្រុមហ៊ុន ARUP Engineering Consultants*






*រូបភាពទី២៣៖ វេទិកាពិភាក្សាពីបញ្ញាត្តកម្ម-ការអនុវត្តគោលនយោបាយនៃការប្រែប្រួលពិភពលោក*

### ៤.៤.២ វេទិកាទឹកពិភពលោក World Water Forum

តាមរយៈគម្រោង WASH-FIN សមាគមបានចូលរួមវេទិកាទឹកពិភពលោក ពីថ្ងៃទី២១-២៦ ខែមីនា ឆ្នាំ២០២២ នៅទីក្រុងដាកា ប្រទេស សេណេហ្គាល់។






*រូបភាពទី២៤៖ ការចែករំលែកបទពិសោធន៍គម្រោង WASH-FIN នៅក្នុងប្រទេសកម្ពុជា អំពីការភ្ជាប់គម្លាតអភិបាលកិច្ច និងហិរញ្ញវត្ថុនៅក្នុងវិស័យទឹកស្អាត និងអនាម័យ (WASH)*

### ៤.៤.៣ ទស្សនកិច្ចសិក្សាទៅប្រទេសម៉ាឡេស៊ី

ពីថ្ងៃទី០៧-០៩ ខែធ្នូ ឆ្នាំ២០២២ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានដឹកនាំសមាជិករបស់ខ្លួន ចំនួន ៨ស្ថានីយ ចូលរួមសន្និសីទទឹកអាស៊ី ឆ្នាំ២០២២ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។




*រូបភាពទី២៥៖ ការចែករំលែកបទពិសោធន៍ការងារសមាគមCWA ជាមួយសមាគម និងក្រុមហ៊ុននៃប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី សឹង្ហបុរី ហ្វីលីពីន ក្នុងវេទិកាអ្នកដឹកនាំសមាគមថ្នាក់តំបន់*




*រូបភាពទី២៦៖ កិច្ចពិភាក្សាស្តីពីការបម្រែបម្រួលអាកាសធាតុ និងការគ្រប់គ្រងនិរន្តរភាពនៃទឹក*

# ៥. កម្មវិធីកសាងសមត្ថភាពសមាជិក

## ៥.១ វគ្គបណ្តុះបណ្តាល

### ៥.១.១ វគ្គបណ្តុះបណ្តាលស្តីពីពន្ធដារ

ឆ្នាំ២០២២ សមាគមបានសហការជាមួយមន្ទីរឧវបន និងសាខាពន្ធដារខេត្ត ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី «**កាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធ និងនីតិវិធីនៃការបង់ពន្ធរបស់អាជីវកម្មផ្គត់**

**ផ្គង់ទឹកស្អាត»** បានចំនួន ២វគ្គ ក្នុងគោលបំណងឱ្យអ្នកចូលរួមអាចរៀបរាប់បានពីកាតព្វកិច្ច និងសិទ្ធិរបស់អ្នកជាប់ពន្ធ និងនីតិវិធីក្នុងការចុះបញ្ជីពន្ធដារ និងរបៀបនៃការបង់ពន្ធសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។ វគ្គបណ្តុះបណ្តាលបានរៀបចំនៅទីតាំងដូចខាងក្រោម៖

❖ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ នៅសណ្ឋាគារអាលីសរីឡា នៅខេត្តតាកែវ មានអ្នកចូលរួមសរុបចំនួន ៣៨នាក់ (ស្រី ១៣នាក់)។



*រូបភាពទី២៧៖ វគ្គបណ្តុះបណ្តាលនៅខេត្តតាកែវ*

❖ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ នៅសាលប្រជុំមន្ទីរឧវបន ខេត្តកំពង់ស្ពឺ មានអ្នកចូលរួមសរុប ៣៧នាក់ (ស្រី ៤នាក់)។



*រូបភាពទី២៨៖ វគ្គបណ្តុះបណ្តាលខេត្តកំពង់ស្ពឺ*

## ៥.១.២ វគ្គបណ្តុះបណ្តាលស្តីពីការសន្សំសំចៃថាមពលអគ្គិសនី

❖ ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ ក្រោមកិច្ចសហការពីក្រុមហ៊ុន ជី អ៊ី អឹម គ្រេឌីង សមាគមបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី«**ការសន្សំសំចៃថាមពលអគ្គិសនីសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត**»នៅសណ្ឋាគារ ហ៊ីម៉ារ៉ាវី អ្នកចូលរួមសរុបចំនួន ៣៣នាក់ (ស្រី ៦នាក់)។



*រូបភាពទី២៩៖ វគ្គបណ្តុះបណ្តាលស្តីពី «ការសន្សំសំចៃថាមពលអគ្គិសនី» (សណ្ឋាគារហ៊ីម៉ាវ៉ារី)*

# ៦. ការងារសហការជាមួយដៃគូអភិវឌ្ឍន៍

## ៦.១ គម្រោងគាំទ្រហិរញ្ញប្បទានលើការងារទឹកស្អាត និងអនាម័យ (WASH-FIN)

### ៦.១.១ កិច្ចប្រជុំពិគ្រោះយោបល់ រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត

ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ ក្រោមជំនួយឧបត្ថម្ភពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ តាមរយៈគម្រោង WASH-FIN និងអង្គការវ៉ែតធីអេតកម្ពុជា សមាគមបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងសេវាករផ្គត់ផ្គង់ទឹកស្អាត នៅខេត្តកំពង់ស្ពឺ។ កិច្ចប្រជុំមានអ្នកចូលរួមសរុបចំនួន ៧៣នាក់ (ស្រី ១១នាក់) ក្រោមអធិបតីភាព **ឯកឧត្តម ជា ទិសុទ្ធ** ទីប្រឹក្សារបស់ក្រសួងឧរបន។



*រូបភាពទី៣០៖ រូបថតអនុស្សាវរីយ៍ក្នុងកិច្ចប្រជុំនៅខេត្តកំពង់ស្ពឺ*

### ៦.១.២ វគ្គបណ្តុះបណ្តាល

ថ្ងៃទី២០-២១ ខែមករា ឆ្នាំ២០២២ គម្រោងបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី«**ផែនការសុវត្ថិភាពទឹក**» ជូនប្រតិបត្តិករចំនួន ១២ស្ថានីយ និងមានអ្នកចូលរួមសរុប ១៣នាក់ (ស្រី២នាក់)។



*រូបភាពទី៣១៖ រូបថតវគ្គបណ្តុះបណ្តាលស្តីពី «ផែនការសុវត្ថិភាពទឹក»*

### ៦.១.៣ ការបិទបញ្ចប់ និងការផ្ទេរបញ្ចាំងគម្រោង

ថ្ងៃទី១០-១១ ខែមីនា ឆ្នាំ២០២២ គម្រោងបានរៀបចំសិក្ខាសាលារៀនសូត្រជាមួយភាគីពាក់ព័ន្ធ និងការឆ្លុះបញ្ចាំងចុងក្រោយ ក្នុងគោលបំណងឆ្លុះបញ្ចាំងពីសមិទ្ធិផលនានារបស់គម្រោង WASH-FIN នៅកម្ពុជា។



*រូបភាពទី៣២៖ រូបថតសិក្ខាសាលាបិទបញ្ចប់ និងការឆ្លុះបញ្ចាំងគម្រោង WASH-FIN*

- ❖ សិក្ខាសាលានៅថ្ងៃទី១ មានអ្នកចូលរួមសរុបចំនួន ៤៧នាក់ (ស្រី១០នាក់) ដែលមានសមាសភាពចូលរួមពីប្រតិបត្តិករ ២៩នាក់ បុគ្គលិកសមាគម ១០នាក់ បុគ្គលិកគម្រោង WASH-FIN ៨នាក់ និងតំណាងធនាគារ ១នាក់។
- ❖ សិក្ខាសាលានៅថ្ងៃទី២ មានអ្នកចូលរួមសរុបចំនួន ៥៣នាក់ (ស្រី១៥នាក់) ដែលមានសមាសភាពចូលរួមពីតំណាងក្រសួងឧស្សាហកម្ម... 

## ៦.១.៤ ដំណើរទស្សនកិច្ចសិក្សា កម្ពុជា-ម៉ូហ្សាំប៊ិក

ដំណើរទស្សនកិច្ចសិក្សា កម្ពុជា-ម៉ូហ្សាំប៊ិក បានផ្តល់ឱកាសដល់ប្រតិបត្តិករឯកជន និងសមាគម និងភាគីពាក់ព័ន្ធរបស់រដ្ឋាភិបាលប្រទេសទាំងពីរចូលរួមចែករំលែកបទពិសោធន៍គម្រោង USAID/WASH-FIN ក្នុងការដោះស្រាយបញ្ហា បទប្បញ្ញត្តិ ប្រតិបត្តិការ និងហិរញ្ញវត្ថុក្នុងវិស័យទឹកស្អាត និងអនាម័យ។




*រូបភាពទី៣៣៖ កិច្ចប្រជុំស្វាគមន៍គណៈប្រតិភូប្រទេសម៉ូហ្សាំប៊ិក*

សមាគមបានរៀបចំជូនគណៈប្រតិភូប្រទេសម៉ូហ្សាំប៊ិក ទៅទស្សនកិច្ចសិក្សាចំនួន ៥ទីតាំង រួមមាន៖ ១.ស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំពង់ចំលង ខេត្តកណ្តាល ២.រដ្ឋាករទឹកសាធារណៈតាំងក្រសាំង ខេត្តកំពង់ធំ ៣.រដ្ឋាករទឹកស្វយ័ត ខេត្តសៀមរាប ៤.ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ខោ ប៊ុនហ៊ាត ខេត្តបាត់ដំបង និង ៥.ទឹកស្អាតសហគមន៍ នៅស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង។





*រូបភាពទី៣៤៖ ទស្សនកិច្ចសិក្សាស្ថានីយទឹកស្អាតកំពង់ចំលង រូបភាពទី៣៥៖ បទបង្ហាញរដ្ឋាករទឹកស្វយ័តសៀមរាប*

### ៦.១.៥ ការសិក្សាអំពីអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតឯកជននៅប្រទេសកម្ពុជា



ក្រោមការគាំទ្រពីគម្រោង WASH-FIN សមាគមបានជ្រើសរើសក្រុមការងារប្រមូលទិន្នន័យ ដោយចុះសម្ភាសជាមួយប្រតិបត្តិករសរុបប្រមាណ ១៥៦ ក្នុងគោលបំណងសិក្សាអំពីស្ថានភាពអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតនៅប្រទេសកម្ពុជា។

*រូបភាពទី៣៦៖ កិច្ចសម្ភាសន៍ជាមួយលោក សៀវ ហ៊ួត ម្ចាស់ស្ថានីយទឹកស្អាតស្វាយរមៀត*

## ៦.២ គម្រោងការពង្រឹងមូលដ្ឋានគ្រឹះសម្រាប់សន្តិសុខទឹក នៅកម្រិតស្រុក ក្នុងប្រទេសកម្ពុជា ( WaterAid )

### ៦.២.១ សិក្ខាសាលារៀបចំផែនការគ្រប់គ្រងធនធានទឹកប្រកបដោយបរិយាប័ន្ន

គម្រោងបានធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងធនធានទឹកប្រកបដោយបរិយាប័ន្នសម្រាប់ស្រុកសាមគ្គីមានជ័យ ដោយផ្អែកលើស្ថានភាពជាក់ស្តែងបច្ចុប្បន្ន និងជំរុញឱ្យមានការអនុវត្តសកម្មភាពរួមគ្នា និងការចូលរួមរបស់អ្នកពាក់ព័ន្ធសំខាន់ៗ ជាពិសេសការចូលរួមដ៏មានអត្ថន័យរបស់តំណាងក្រុមជនងាយរងគ្រោះ និងស្ត្រី ក្នុងការគ្រប់គ្រងធនធានទឹក និងវិស័យទឹកស្អាត និងអនាម័យ។



*រូបភាពទី៣៧៖ ការរៀបចំផែនការរបស់ឃុំ*

### ៦.២.២ វគ្គបណ្តុះបណ្តាលស្តីពី«កិច្ចប្រជុំផ្សព្វផ្សាយតាមខ្នងផ្ទះអំពីសារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាត»

ថ្ងៃទី១៥-១៦ ខែកញ្ញា ឆ្នាំ២០២២ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការរៀបចំកិច្ចប្រជុំផ្សព្វផ្សាយតាមខ្នងផ្ទះអំពី«**សារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាត**» ជូនដល់អាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ដែលមានអ្នកចូលរួមសរុបចំនួន ១៨នាក់ (ស្រី ៨នាក់) នៅសាលាស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។



*រូបភាពទី៣៨៖ វគ្គបណ្តុះបណ្តាល នៅសាលាស្រុកសាមគ្គីមានជ័យ*

### ៦.២.៣ រៀបចំកិច្ចប្រជុំផ្សព្វផ្សាយតាមសហគមន៍ «សារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាត»

ថ្ងៃទី២៥-២៦ ខែសីហា ឆ្នាំ២០២២ សមាគមបានសហការជាមួយប្រតិបត្តិករក្នុងការរៀបចំកិច្ចប្រជុំផ្សព្វផ្សាយតាម សហគមន៍ស្តីពី **«សារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាត»** ជូនប្រជាពលរដ្ឋ។ អ្នកចូលរួមសរុបចំនួន ៩១នាក់ (ស្រី ៦៦នាក់) នៅក្នុងឃុំចំនួន ៣ ក្នុងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។



*រូបភាពទី៣៩៖ កិច្ចប្រជុំសហគមន៍ នៅឃុំពាម ស្រុកសាមគ្គីមានជ័យ*

### ៦.២.៤ វគ្គបណ្តុះបណ្តាលស្តីពី «បច្ចេកទេសនៃការផលិតទឹកស្អាត និងការតេស្តគុណភាពទឹកស្អាត» និង «វិធានការកាត់បន្ថយផលប៉ះពាល់ពីគ្រោះរាំងស្ងួត និងទឹកជំនន់សម្រាប់ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត»

ថ្ងៃទី២៣-២៤ ខែមិថុនា ឆ្នាំ២០២២ សមាគមបានផ្តល់វគ្គបណ្តុះបណ្តាលស្តីពី «បច្ចេកទេសនៃការផលិតទឹកស្អាត និងការតេស្តគុណភាពទឹកស្អាត» និង «វិធានការកាត់បន្ថយផលប៉ះពាល់ពីគ្រោះរាំងស្ងួត និងទឹកជំនន់សម្រាប់ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត» ជូនដល់អាជ្ញាធរមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ដែលមានអ្នកចូលរួមសរុបចំនួន ២២នាក់ ស្រី៦នាក់ នៅសាលាស្រុកសាមគ្គីមានជ័យ។

### ៦.២.៥ វគ្គបង្វឹកស្តីពី «ការតេស្តគុណភាពទឹកស្អាត»

នៅខែធ្នូ ឆ្នាំ២០២២ សមាគមបានផ្តល់វគ្គបង្វឹកស្តីពី **«ការតេស្តគុណភាពទឹកស្អាត»** ជូនដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចំនួន ៦ស្ថានីយ ដែលប្រតិបត្តិការនៅក្នុងស្រុកសាមគ្គីមានជ័យ។ គម្រោងក៏បានផ្តល់ជូននូវឧបករណ៍តេស្តគុណភាពទឹក និងឧបករណ៍វាស់សម្ពាធទឹកជូនដល់ប្រតិបត្តិករទាំង ៦ស្ថានីយ ដើម្បីធ្វើតេស្តគុណភាពទឹកស្អាតលើប៉ារ៉ាម៉ែត្រប្រចាំថ្ងៃ។



*រូបភាពទី៤០៖ តំណាងអង្គការតែជីអេតប្រគល់ឧបករណ៍តេស្តជូនប្រតិបត្តិករ*

### ៦.២.៦ សិក្ខាសាលាតម្រង់ទិសស្តីពី «ប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត» និង «ការប្រកួតប្រជែង វិស័យឯកជនគំរូក្នុងការផ្តល់សេវាទឹកស្អាតនៅក្នុងសហគមន៍»

ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២ សមាគមបានសហការជាមួយមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ឆ្នាំងក្នុងការរៀបចំសិក្ខាសាលាតម្រង់ទិសស្តីពី**«ប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត»** ជូនប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតក្នុងស្រុកសាមគ្គីមានជ័យ ដើម្បីស្វែងយល់អំពីឯកសារគតិយុត្តពាក់ព័ន្ធទៅនឹងសេវាទឹកស្អាតតាមបំពង់ និងរៀបរាប់បានពីចំណុចសំខាន់ៗដែលមាននៅក្នុងប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់

ទឹកស្អាត។ សិក្ខាសាលានេះក៏មានការចែករំលែកពីបទពិសោធន៍ល្អៗក្នុងការធ្វើទីផ្សារសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាតដើម្បីបង្កើនតំណ ដោយ**អ្នកស្រី ស៊ឹម សៀមនី** ម្ចាស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំការលើ។

នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ អង្គការវ៉ែតធីអេតកម្ពុជាបានសហការជាមួយរដ្ឋបាលស្រុកសាមគ្គីមានជ័យ មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ឆ្នាំង ក្នុងការរៀបចំសិក្ខាសាលាសេចក្តីណែនាំស្តីពី **«ការប្រកួតប្រជែង វិស័យឯកជនគំរូក្នុងការផ្តល់សេវាទឹកស្អាតនៅក្នុងសហគមន៍»**។ សិក្ខាសាលានេះមានគោលបំណងជ្រើសរើសប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតគំរូក្នុងការផ្តល់សេវាទឹកស្អាតនៅក្នុងសហគមន៍។

## ៦.៣ គម្រោងការពង្រឹងគណនេយ្យភាពរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតដើម្បីលើកកម្ពស់សេវាកម្មទឹកស្អាត (WaterAid)

### ៦.៣.១ វគ្គបណ្តុះបណ្តាល

សមាគមបានរៀបចំវគ្គបណ្តុះបណ្តាល **«តួនាទី និងការទទួលខុសត្រូវលើសេវាកម្មផ្គត់ផ្គង់ទឹកស្អាត»** និង**«បច្ចេកទេសមូលដ្ឋាននៃការផលិតទឹកស្អាត និងការតេស្តគុណភាពទឹកស្អាត»** ចំនួន ៤វគ្គ ជូនអាជ្ញាធរស្រុក អាជ្ញាធរឃុំ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត នៅ៖

1. ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដែលមានអ្នកចូលរួមសរុប ១៥នាក់ ស្ត្រី ៧នាក់
2. ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដែលមានអ្នកចូលរួមសរុប ២៤នាក់ ស្ត្រី ៩នាក់
3. ស្រុកអង្គស្នួល ខេត្តកណ្តាល ដែល មានអ្នកចូលរួមសរុប ២៧នាក់ ស្ត្រី ១២នាក់
4. ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានអ្នកចូលរួមសរុប ១៨នាក់ ស្ត្រី ៥នាក់។



*រូបភាពទី៤១៖ វគ្គបណ្តុះបណ្តាលនៅស្រុកអង្គស្នួល*

### ៦.៣.២ សិក្ខាសាលាតម្រង់ទិសស្តីពី«ប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត»

សមាគមបានសហការជាមួយមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្តកំពង់ស្ពឺ ក្នុងការរៀបចំសិក្ខាសាលាតម្រង់ទិសស្តីពី **«ប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត»** នៅសណ្ឋាគារផាមរីវើ (Palm River Hotel) ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។ អ្នកចូលរួមសរុបមានចំនួន ៤៣នាក់ ស្រី៧នាក់។



*រូបភាពទី៤២៖ សិក្ខាសាលាតម្រង់ទិសស្តីពី ប្រកាសអនុញ្ញាតឲ្យអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត*

## ៦.៣.៣ វគ្គបង្វឹក

សមាគមបានសហការជាមួយរដ្ឋបាលស្រុកចំនួន៥ និងមន្ទីរឧ.រ.ប.ន ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ដើម្បីរៀបចំវគ្គបង្វឹកស្តីពី «**ការតេស្តគុណភាពទឹកស្អាត**» ជូនដល់អាជ្ញាធរឃុំ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន នៅក្នុងឃុំចំនួន ៣៣ឃុំ ដូចខាងក្រោម៖

១. ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង៖ ចំនួន ១០ឃុំ មានអ្នកចូលរួមសរុបចំនួន ៨៥នាក់ (ស្រី ២២នាក់)
២. ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ៖ ចំនួន ៦ឃុំ មានអ្នកចូលរួមសរុបចំនួន ៥៣នាក់ (ស្រី ១៧នាក់)
៣. ស្រុកថ្ពង ខេត្តកំពង់ស្ពឺ៖ ចំនួន ៤ឃុំ មានអ្នកចូលរួមសរុបចំនួន៣២នាក់ (ស្រី៨នាក់)
៤. ស្រុកអង្គស្នួល ខេត្តកណ្តាល៖ ចំនួន ១០ឃុំ មានអ្នកចូលរួមសរុបចំនួន ៧៩នាក់ (ស្រី ១៩នាក់)
៥. ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល៖ ចំនួន ៣ឃុំ មានអ្នកចូលរួមសរុបចំនួន ២២នាក់ (ស្រី ៧នាក់)។




*រូបភាពទី៤៣៖ វគ្គបង្វឹកនៅឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ*

## ៦.៣.៤ កិច្ចប្រជុំថ្នាក់ឃុំ

សមាគមបានសហការជាមួយរដ្ឋបាលស្រុកចំនួន៣ និងមន្ទីរឧវបន ខេត្តកំពង់ស្ពឺ និងខេត្តកណ្ដាល រៀបចំកិច្ចប្រជុំថ្នាក់ឃុំស្ដីពី **«សេវាផ្គត់ផ្គង់ទឹកស្អាត»** បានចំនួន ១៨ឃុំ។ សមាសភាពចូលរួមពីតំណាងមន្ទីរឧវបន មន្ត្រីរដ្ឋបាលស្រុក មេឃុំ និងសមាជិកក្រុមប្រឹក្សាឃុំ មេភូមិ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត តំណាងសហគមន៍ តំណាងមណ្ឌលសុខភាព តំណាងសាលារៀន និងតំណាងប៉ុស្តិ៍ប៉ូលីស។ ជាលទ្ធផលកិច្ចប្រជុំបានរៀបចំនៅទីតាំងដូចខាងក្រោម៖



*រូបភាពទី៤៤៖ ការសម្របសម្រួលកិច្ចប្រជុំថ្នាក់ឃុំ*

១. ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ៖ ចំនួន ៦ឃុំ មានអ្នកចូលរួមសរុបចំនួន ១៩៨នាក់ (ស្រី ៣៤នាក់)

២. ស្រុកថ្ពង ខេត្តកំពង់ស្ពឺ៖ ចំនួន ២ឃុំ មានអ្នកចូលរួមសរុបចំនួន ៤០នាក់ (ស្រី ១០នាក់)

៣. ស្រុកអង្គស្នួល ខេត្តកណ្ដាល៖ ចំនួន ១០ឃុំ មានអ្នកចូលរួមសរុបចំនួន ៣៤៨នាក់ (ស្រី ៧០នាក់)។

## ៦.៣.៥ កិច្ចប្រជុំកិច្ចប្រជុំពិគ្រោះយោបល់លើការអនុវត្តគម្រោង

សមាគមបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើការអនុវត្តគម្រោងរវាងមន្ទីរពាក់ព័ន្ធ អង្គការវ៉តធីអេតកម្ពុជា បានចំនួន ៣ប្រជុំ ដែលរៀបចំនៅ៖

1. សាលប្រជុំមន្ទីរ ឧវបន ខេត្តកណ្ដាល៖ មានអ្នកចូលរួមសរុប ៩នាក់ (ស្រី៣នាក់)
2. សាលប្រជុំមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ឆ្នាំង៖ មានអ្នកចូលរួមសរុប ៨នាក់ (ស្រី៤នាក់)
3. សាលប្រជុំមន្ទីរ ឧវបន ខេត្តកំពង់ស្ពឺ៖ មានអ្នកចូលរួមសរុប ៣២នាក់ (ស្រី៥នាក់)។




*រូបភាពទី៤៥៖ ការប្រគល់សម្ភារៈធ្វើតេស្តគុណភាពទឹក និងឧបករណ៍តេស្តសម្ភាធទឹកដល់មន្ទីរ ឧវបន ខេត្តកណ្ដាល*

## ៦.៣.៦ កិច្ចប្រជុំឆ្លុះបញ្ចាំង

សមាគមបានរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងលើការអនុវត្តគម្រោងរវាងមន្ទីរពាក់ព័ន្ធ អង្គការវ៉តធឺអេតកម្ពុជា សមាគម និងប្រតិបត្តិករ បានចំនួន ២ប្រជុំ ដែលរៀបចំនៅ៖

1. សាលប្រជុំរបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតលង្វែក នៅខេត្តកំពង់ឆ្នាំង៖ មានអ្នកចូលរួមសរុប ១៧នាក់ (ស្រី៤នាក់)។
2. សាលប្រជុំរបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតបែកចាន នៅខេត្តកណ្ដាល៖ មានអ្នកចូលរួមសរុប ១៣នាក់ (ស្រី២នាក់)។

## ៦.៣.៧ ជួយឧបត្ថម្ភធនតំណភ្ជាប់បណ្ដាញទឹកស្អាតជូនគ្រួសារក្រីក្រ

សមាគមបានសម្របសម្រួលភ្ជាប់សេវាទឹកស្អាតជូនគ្រួសារក្រីក្របានចំនួន ៤១៧គ្រួសារ និងមានស្ថានីយទឹកស្អាតចំនួន ៨ ដែលបានចូលរួមអនុវត្តគម្រោង៖ ១). ក្រុមហ៊ុន លង្វែក ឌីវេឡុបម៉ិន វ៉តធើរ ស៊ីបផ្លាយ ឯ.ក. ២). ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ក្ដុល ៣). ស្ថានីយផ្គត់ផ្គង់ទឹកស្អាតសាលាលេខ៥ ៤).ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ហេង អៀម ៥). ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ស្វាយជុក ៦). ស្ថានីយផ្គត់ផ្គង់ទឹកស្អាតពាម ៧). ស្ថានីយផ្គត់ផ្គង់ទឹកស្អាត អំពិលទឹក និង៨). ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ព្រៃករាំង។



*រូបភាពទី៤៦៖ រូបភាពគ្រួសារក្រីក្រទទួលបានទឹកស្អាតនៅ ស្រុកសាមគ្គី*

## ៦.៣.៨ ទស្សនកិច្ចសិក្សារបស់ម្ចាស់ជំនួយ WaterAid

សមាគមបានសម្របសម្រួលដំណើរទស្សនកិច្ចសិក្សាស្វែងយល់អំពីប្រព័ន្ធសម្អាតទឹកនៅក្រុមហ៊ុន លង្វែក ឌីវេឡុបម៉ិន វ៉តធើរ ស៊ីបផ្លាយ ឯ.ក តាមរយៈគម្រោង«ការពង្រឹងគណនេយ្យភាពរបស់សេវាករផ្គត់ផ្គង់ទឹកស្អាតដើម្បីលើកកម្ពស់សេវាកម្មទឹកស្អាតដែលទទួលបានការឧបត្ថម្ភគាំទ្រពីអង្គការវ៉តធឺអេតកម្ពុជា។



*រូបភាពទី៤៧៖ រូបភាពទស្សនកិច្ចសិក្សារបស់ម្ចាស់ជំនួយ WaterAid*

## ៦.៤ បង្កើនការទទួលសេវាទឹកស្អាត និងអនាម័យដែលធន់នឹងអាកាសធាតុសម្រាប់ជនងាយរងគ្រោះនៅតាមសហគមន៍ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីផ្តើមក្នុងវិស័យទឹកស្អាត និងអនាម័យប្រកបដោយបរិយាប័ន្ន ( WaterAid )

### ៦.៤.១ សិក្ខាសាលាផ្សព្វផ្សាយគម្រោង

សមាគមបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយគម្រោង «**បង្កើនការទទួលសេវាទឹកស្អាត និងអនាម័យដែលធន់នឹងអាកាសធាតុសម្រាប់ជនងាយរងគ្រោះនៅតាមសហគមន៍ និងភាពជាអ្នកដឹកនាំរបស់ស្ត្រីផ្តើមក្នុងវិស័យទឹកស្អាត និងអនាម័យប្រកបដោយបរិយាប័ន្ន**» ចំនួន ២ប្រជុំ។ សមាសភាពអ្នកចូលរួមអញ្ជើញមកពី តំណាងមន្ទីរឧវបន តំណាងមន្ទីរអភិវឌ្ឍន៍ជនបទ តំណាងរដ្ឋបាលស្រុក ក្រុមប្រឹក្សាឃុំ តំណាងសមាគមជនពិការ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងបុគ្គលិកអង្គការវ៉េតជីអេតកម្ពុជា។

1. នៅសាលប្រជុំសាលាស្រុកល្វាឯមមានអ្នកចូលរួមចំនួន ២២នាក់ (ស្រី ១០នាក់)។
2. នៅសាលប្រជុំសាលាស្រុកស្អាងមានអ្នកចូលរួមចំនួន ១៨នាក់(ស្រី ៩នាក់)។



*រូបភាពទី៤៨៖ សិក្ខាសាលាផ្សព្វផ្សាយគម្រោងនៅក្នុងសាលប្រជុំសាលាស្រុកល្វាឯម*

### ៦.៤.២ វគ្គបង្វឹក

សមាគមបានរៀបចំវគ្គបង្វឹកស្តីពី «**ការតេស្តគុណភាពទឹកស្អាត**» និង«**សេវាកម្មអតិថិជន**» ដល់បុគ្គលិករបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ដោយមានការជួបជុំផ្ទាល់នៅស្ថានីយចំនួន ៤ទីតាំងដូចជា៖



១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតកោះខ្សាច់ទន្លា
២. ស្ថានីយទឹកស្អាត ឡេងខៀវ ព្រែកអំបិល
៣. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតស្វាយប្រទាល
៤. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជនត្រើយស្លា នៅក្នុងស្រុកស និងចំនួន ១ទីតាំង នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាតព្រែកឫស្សីក្នុងស្រុកល្វាឯម។

*រូបភាពទី៤៩៖ ការធ្វើជ្យាតេស្ត (Jar Test) នៅទឹកស្អាត ស្វាយប្រទាល ស្រុកស្អាង*

### ៦.៤.៣ ទិន្នន័យគ្រួសារក្រីក្រ

សមាគមបានសហការជាមួយសមាគមជនពិការស្រុកស្អាងដើម្បីប្រមូលទិន្នន័យដើមគ្រាអំពីគ្រួសារ ក្រីក្រដែលបានភ្ជាប់ទឹកស្អាតរួច និងមិនទាន់បានភ្ជាប់ នៅក្នុងឃុំចំនួន ៥ គឺ ១). ឃុំស្វាយប្រទាល ២). ឃុំព្រែកអំបិល ៣). ឃុំកោះខែល ៤). ឃុំកោះខ្សាច់ទន្លា និង ៥). ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្ដាល ដែលជាតំបន់សេវាកម្មរបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតក្នុងស្រុកស្អាង។



*រូបភាពទី៥០៖ បុគ្គលិកសមាគមចុះប្រមូលទិន្នន័យគ្រួសារក្រីក្រ*

### ៦.៤.៤ វគ្គបណ្ដុះបណ្ដាល

សមាគមបានសហការជាមួយរដ្ឋបាលស្រុក និងមន្ទីរឧរបន ខេត្តកណ្ដាល រៀបចំវគ្គបណ្ដុះបណ្ដាលចំនួន ៤លើកដូចខាងក្រោម៖

១. វគ្គបណ្ដុះបណ្ដាលស្ដីពី «**តួនាទី និងការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងសហគមន៍ចំពោះសេវាកម្មទឹកស្អាត**» និង«**បច្ចេកទេសនៃការផលិតទឹកស្អាត និងការតេស្តគុណភាពទឹកស្អាត**» ព្រមទាំងផ្ដល់ឧបករណ៍តេស្តគុណភាពទឹក និងវាស់សម្ពាធទឹកដល់អាជ្ញាធរស្រុកទាំងពីរ ដែលមានអ្នកចូលរួមសរុប ៤៣នាក់ (ស្រី១៣នាក់)។



*រូបភាពទី៥១៖ វគ្គបណ្ដុះបណ្ដាល ស្រុកល្វាឯម ខេត្តកណ្ដាល*

២. វគ្គបណ្ដុះបណ្ដាលស្ដីពី «**វិធានការកាត់បន្ថយផលប៉ះពាល់ពីគ្រោះរាំងស្ងួត និងទឹកជំនន់ សម្រាប់ការផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាត**» មានសមាសភាពចូលរួមពីតំណាងមន្ទីរឧ.វ.ប.ន និងតំណាងមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកណ្ដាល តំណាងរដ្ឋបាលស្រុកល្វាឯម ក្រុមប្រឹក្សាឃុំ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ដែលមានអ្នកចូលរួមសរុបចំនួន ២៨នាក់ (ស្រី ៥នាក់)។



*រូបភាពទី៥២៖ កិច្ចពិភាក្សាក្រុមក្នុងវគ្គបណ្ដុះបណ្ដាល ស្រុកល្វាឯម*

៣. វគ្គបណ្ដុះបណ្ដាលការរៀបចំកិច្ចប្រជុំផ្សព្វផ្សាយតាមខ្នងផ្ទះស្ដីពី **«សារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាត»** ចំនួន២វគ្គ មានសមាសភាពចូលរួមពីតំណាងរដ្ឋបាលស្រុក ក្រុមប្រឹក្សាឃុំ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ដែលរៀបចំនៅទីតាំងដូចខាងក្រោម៖

ក. ស្រុកស្អាង៖ មានអ្នកចូលរួមសរុបចំនួន ២១នាក់ (ស្រី ៩នាក់)
ខ. ស្រុកល្វាឯម៖ មានអ្នកចូលរួមសរុបចំនួន ១៤នាក់ (ស្រី ៧នាក់)
សមាគមក៏បានចែកសម្ភារៈផ្សព្វផ្សាយជូនរដ្ឋបាលស្រុក ឃុំ និងប្រតិបត្តិករក្នុងស្រុកទាំងពីរផងដែរ។



*រូបភាពទី៥៣៖ វគ្គបណ្ដុះបណ្ដាលនៅស្រុកស្អាង ខេត្តកណ្ដាល*

៤. ការបង្ហឹកស្ដីពី «**ការតេស្តគុណភាពទឹកស្អាត**» រយៈពេលកន្លះថ្ងៃ សាលាឃុំចំនួន៦ សម្រាប់ឃុំគោលដៅទាំង១១។ គម្រោងបានផ្ដល់ឧបករណ៍វាស់ក្លរសំណល់ និងវាស់សម្ពាធទឹកដល់អាជ្ញាធរឃុំទាំង ១១ផងដែរ។

*តារាងទី២៖ សមាសភាពអ្នកចូលរួមក្នុងវគ្គបង្ហឹក*

| ល.រ | ទីតាំង | ឃុំចូលរួម | កាលបរិច្ឆេទ | ចំនួន | | |
|---|---|---|---|---|---|---|
| | | | | ស្រី | ប្រុស | សរុប |
| 1 | ឃុំត្រើយស្លា | ឃុំត្រើយស្លា<br>ឃុំប្រាសាទ | ១៧ តុលា ២០២២ | 4 | 6 | 10 |
| 2 | សាលាឃុំស្វាយប្រទាល | ឃុំស្វាយប្រទាល<br>ឃុំកោះខ្សាច់ទន្លា | | 4 | 6 | 10 |
| 3 | សាលាឃុំកោះខែល | ឃុំកោះខែល<br>ឃុំព្រែកអំបិល | ១៨ តុលា ២០២២ | 5 | 7 | 12 |
| 4 | សាលាឃុំអរិយក្សត្រ | ឃុំអរិយក្សត្រ<br>ឃុំសារិកាកែវ | ១៩ តុលា ២០២២ | 5 | 5 | 10 |
| 5 | សាលាឃុំពាមឧកញ៉ាអុង | ឃុំពាមឧកញ៉ាអុង<br>ឃុំកោះរះ | | 6 | 9 | 15 |
| 6 | សាលាឃុំព្រែកឫស្សី | ឃុំព្រែកឫស្សី | ២០ តុលា ២០២២ | 2 | 6 | 8 |
| សរុប | | | | 26 | 39 | 65 |



*រូបភាពទី៥៤៖ អ្នកចូលរួមអនុវត្តតេស្តក្លរសំណល់នៅសាលាឃុំកោះខែល*

## ៦.៤.៥ ការរៀបចំកិច្ចប្រជុំថ្នាក់ក្រោមជាតិ និងកិច្ចប្រជុំផ្លុះបញ្ចាំងគម្រោង

សមាគមបានសហការជាមួយរដ្ឋបាលស្រុក និងមន្ទីរឧ.វ.ប.ន ដើម្បីរៀបចំ «**កិច្ចប្រជុំថ្នាក់ក្រោមជាតិ**» និង «**កិច្ចប្រជុំឆ្លុះបញ្ចាំងគម្រោង**» នៅសាលាស្រុកស្អាង និងល្វាឯម។ កិច្ចប្រជុំរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ (ស្រុក/ឃុំ) និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត រៀបចំឡើងឱ្យមានការជួបជុំគ្នារវាងភាគីពាក់ព័ន្ធទាំងអស់។

- **ស្រុកស្អាង (២៦ ធ្នូ ២០២២)៖** មានអ្នកចូលរួមសរុបចំនួន ២៦នាក់ (ស្រី ៩នាក់)
- **ស្រុកល្វាឯម (២៧ ធ្នូ ២០២២)៖** មានអ្នកចូលរួមសរុបចំនួន ១៩នាក់ (ស្រី ១០នាក់)។



*រូបភាពទី៥៥៖ កិច្ចប្រជុំថ្នាក់ក្រោមជាតិនៅសាលាស្រុកស្អាង*



*រូបភាពទី៥៦៖ កិច្ចប្រជុំឆ្លុះបញ្ចាំងគម្រោងនៅសាលាស្រុកល្វាឯម*

## ៦.៤.៦ ជំនួយឧបត្ថម្ភធនលើតំណភ្ជាប់បណ្តាញទឹកស្អាតជូនគ្រួសារក្រីក្រ

ប្រជាពលរដ្ឋ ៣០៥គ្រួសារ បានភ្ជាប់ទឹកស្អាតប្រើប្រាស់ក្រោមជំនួយបដិភាគរបស់ប្រតិបត្តិករ និងអង្គការវ៉េតធីអេត ក្នុងនោះមាន ១). ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឡេងខៀវ ព្រែកអំបិល ២). ស្ថានីយផ្គត់ផ្គង់ទឹកស្អាតស្វាយប្រទាល ៣). ស្ថានីយផ្គត់ផ្គង់ទឹកស្អាតត្រើយស្លា និង ៤). ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំកោះខ្សាច់ទន្លា។



*រូបភាពទី៥៧៖ គ្រួសារក្រីក្របានភ្ជាប់ទឹកស្អាត ស្រុកស្អាង*

## ៦ ៧.៤.ផលិតសម្ភារៈផ្សព្វផ្សាយរូបភាពផ្ទាំងធំអំពីភាពធន់នឹងការប្រែប្រួលអាកាសធាតុ



## ៦.៥ បង្កើននូវភាពធន់ នឹងអាកាសធាតុសម្រាប់ការផ្គត់ផ្គង់ទឹកស្អាត ដល់ឃុំដែលមានហានិភ័យខ្ពស់ប្រឈមនៅនឹងបម្រែបម្រួលអាកាសធាតុ ( UNICEF )

### ៦.៥.១ វឌ្ឍនភាពរបស់គម្រោងលើការពង្រីកបណ្តាញ

ស្ថានីយផ្គត់ផ្គង់ទឹកស្អាតវាលពង់ ស្ថានីយផ្គត់ផ្គង់ទឹកស្អាតក្រាំងចេក និងស្ថានីយផ្គត់ផ្គង់ទឹកស្អាតប៉េង ហុង បានពង្រីកបណ្តាញចែកចាយទឹកស្អាតបន្ថែមបានប្រវែងសរុបចំនួន ៧៩,១៦៤ម៉ែត្រ ធៀបទៅនឹងគោលដៅចំនួន ៤៨,៧៥០ម៉ែត្រ។ លើសពីនេះទៅទៀត ស្ថានីយទាំងបីបានបង្កើនតំណថ្មីបន្ថែមបានចំនួន ១,០១៤តំណ នៅក្នុងតំបន់ដែលបានពង្រីកបណ្តាញថ្មី។

### ៦.៥.២ វឌ្ឍនភាពរបស់គម្រោងលើការកែលម្អប្រភពទឹក

គម្រោងបានបញ្ចប់ដោយជោគជ័យលើការកែលម្អប្រភពទឹ ដោយបានខួងអណ្តូងចំនួន ៧ សម្រាប់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ប៉េងហុង ចំនួន ៤អណ្តូង និងស្ថានីយផ្គត់ផ្គង់ទឹកស្អាតសេកគង់ ចំនួន ៣អណ្តូង។ គម្រោងក៏បានដំឡើងម៉ូទ័របូមគ្រប់អណ្តូង ឧបករណ៍តាមដានកម្ពស់ទឹកក្រោមដីចំនួន២អណ្តូង (១គ្រឿងសម្រាប់១ស្ថានីយ) និងបានដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យចំនួន២ ដែលមានកំលាំង១៥kw/h សម្រាប់ស្ថានីយទាំងពីរ។ ជាលទ្ធផលប្រជាពលរដ្ឋចំនួន ២,៣៣០ខ្នងផ្ទះទទួលបានអត្ថប្រយោជន៍ពីការកែលម្អប្រភពទឹក។

### ៦.៥.៣ វឌ្ឍនភាពរបស់គម្រោងលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត

គម្រោងបានសម្របសម្រួលឱ្យប្រតិបត្តិករអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតបន្ថែមដូចខាងក្រោម៖

- គម្រោងបានផ្តល់បដិភាគបំពង់ទឹកស្អាតប្រវែង ២២,៤០០ម៉ែត្រ ដល់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតបូរីជលសារ។ ទន្ទឹមនឹងនេះ ស្ថានីយក៏បានចូលរួមចំណែកក្នុងការពង្រីកអាងស្តុកទឹកស្អាតដែលមានសមត្ថភាព ៨០ម$^{៣}$។
- គម្រោងបានផ្តល់បដិភាគបំពង់ទឹកស្អាតប្រវែង ១៣,៨១៨ម៉ែត្រ ដល់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សេកគង់។ ស្ថានីយក៏បានចូលរួមចំណែកក្នុងការពង្រីកអាងប្រព្រឹត្តិកម្មទឹកដែលមានសមត្ថភាព ១៨០ម$^{៣}$/ម៉ និងអាងស្តុកទឹកស្អាតដែលមានសមត្ថភាព ១,៤០០ម$^{៣}$។

ជាលទ្ធផលប្រជាពលរដ្ឋចំនួន ២,៤០៥ខ្នងផ្ទះទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត។

### ៦.៥.៤ វឌ្ឍនភាពរបស់គម្រោងលើការចែករំលែកចំណេះដឹង និងការកសាងសមត្ថភាព

- បានរៀបចំវគ្គបណ្តុះបណ្តាល តាមប្រព័ន្ធអនឡាញចំនួន ១វគ្គ និងវគ្គបណ្តុះបណ្តាលផ្ទាល់ចំនួន១វគ្គ អំពីគោលការណែនាំស្តីពី **«ផែនការសុវត្ថិភាពទឹកដែលធន់នឹងអាកាសធាតុ»** ដែលមានប្រតិបត្តិករចូលរួមសរុបចំនួន ៣១៣នាក់។
- បានសិក្សាវាយតម្លៃអំពីការប្រើប្រាស់ទឹកក្រោមដីរបស់ប្រតិបត្តិករក្នុងខេត្តកំពង់ស្ពឺ ស្វាយរៀង តាកែវ ត្បូងឃ្មុំ កំពង់ចាម និងព្រៃវែង។

- បានបញ្ចប់ការកែសម្រួលលើគោលការណ៍ផែនការសុវត្ថិភាពទឹកដែលធន់នឹងអាកាសធាតុសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងបានដាក់ជូនក្រសួងឧរបន ដើម្បីអនុម័តឲ្យប្រើប្រាស់ជាផ្លូវការ។
- បានរៀបចំករណីសិក្សាអំពីបទពិសោធន៍មុន និងក្រោយការអនុវត្តគម្រោងរបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំនួន ៥ រួមមាន៖ ១.ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ប៉េង ហុង ២.ស្ថានីយផ្គត់ផ្គង់ទឹកស្អាត វាល ពង់ ៣.ស្ថានីយផ្គត់ផ្គង់ទឹកស្អាត សេក គង់ ៤.ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ក្រាំងចេក និង ៥. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បូរីជលសារ។
- បានបង្វឹកផ្ទាល់ដល់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតចំនួន ៥ស្ថានីយខាងលើ ស្ដីពីបច្ចេកទេសក្នុងការផលិត ការធ្វើតេស្តគុណភាពទឹក ការថែទាំប្រព័ន្ធសម្អាត និងការផ្គត់ផ្គង់ទឹកស្អាត។



*រូបភាពទី៥៨៖ ការពង្រឹងសមត្ថភាពដល់បុគ្គលិកស្ថានីយផ្គត់ផ្គង់ទឹកស្អាត*

## ៦.៥.៦ សកម្មភាពចុះត្រួតពិនិត្យ និងតាមដានគម្រោង

បុគ្គលិកគម្រោងបានចុះត្រួតពិនិត្យ និងតាមដានសកម្មភាពរបស់គម្រោងជាប្រចាំទៅតាមផែនការ ដើម្បីជំរុញការអនុវត្តគម្រោងឱ្យសម្រេចបានទៅតាមគោលដៅ។ ខាងក្រោមនេះជាសកម្មភាពមួយចំនួននៃការចុះត្រួតពិនត្យ និងតាមដាន៖



*រូបភាពទី៥៩៖ ស្ថានីយផ្គត់ផ្គង់ទឹកស្អាត បុរីជលសារ ខេត្តតាកែវ*



*រូបភាពទី៦០៖ សកម្មភាពជីកដីកប់បំពង់ទឹកស្អាត របស់ស្ថានីយទឹកស្អាត ក្រាំងចេក ខេត្តកំពង់ស្ពឺ*



*រូបភាពទី៦១៖ សកម្មភាពតបំពង់ទឹកស្អាត របស់ស្ថានីយទឹកស្អាត វាលពង់ ខេត្តកំពង់ស្ពឺ*



*រូបភាពទី៦២៖ ការតម្លើងម៉ូទ័រ ប៊ូមទឹកអណ្តូងនៅស្ថានីយ បាត់ដឹង និងស្ថានីយទឹកស្អាត ប៉េងហុង*

## ៦.៦ គម្រោងសម្ព័ន្ធភាពដើម្បីអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌ ( Aide et Action )

### ៦.៦.១ សិក្ខាសាលាផ្សព្វផ្សាយគម្រោងថ្នាក់ខេត្ត

គម្រោងបានរៀបចំសិក្ខាសាលាដើម្បីផ្សព្វផ្សាយ អំពីគម្រោងទៅដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងអាជ្ញាធរភូមិឃុំ ចំនួន ២លើកដូចខាងក្រោម៖

- ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ សិក្ខាសាលាផ្សព្វផ្សាយគម្រោងតាមអនឡាញ សម្រាប់ខេត្តកំពត ដែលមានសមាសភាពអ្នកចូលរួមមកពី តំណាងក្រសួង/មន្ទីរឧស្សាហកម្ម... តំណាងមន្ទីរអភិវឌ្ឍន៍ជនបទ តំណាងមន្ទីរអប់រំ យុវជន និងកីឡា តំណាងរដ្ឋបាលខេត្ត/ស្រុក ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងតំណាងមកពីអង្គការ Aide et Action សរុបចំនួន ២៦នាក់។
- ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ សិក្ខាសាលាផ្សព្វផ្សាយគម្រោងតាមអនឡាញ សម្រាប់ខេត្តកែប ខេត្តព្រះសីហនុ និងខេត្តកោះកុង ដែលមានសមាសភាពអ្នកចូលរួមមកពី តំណាងក្រសួង/មន្ទីរឧស្សាហកម្ម... តំណាងមន្ទីរអភិវឌ្ឍន៍ជនបទ តំណាងមន្ទីរអប់រំ យុវជន និងកីឡា តំណាងរដ្ឋបាលខេត្ត/ស្រុក ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន សរុបចំនួន ៤៧នាក់។




*រូបភាពទី៦៣៖ សិក្ខាសាលាផ្សព្វផ្សាយ គម្រោងតាម អនឡាញ ( Zoom Call )*

### ៦.៦.២ សិក្ខាសាលាផ្សព្វផ្សាយគម្រោងថ្នាក់ស្រុក

គម្រោងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយគម្រោងចំនួន ១០ស្រុក/ក្រុង ដែលមានសមាសភាពចូលរួមសរុប ១៤៦នាក់ (ស្រី ២១នាក់) និងរៀបចំនៅទីតាំងដូចខាងក្រោម៖

- ខេត្តកំពត បានប្រជុំចំនួន ២ស្រុកគឺ ស្រុកទឹកឈូ និងស្រុកកំពង់ត្រាច
- ខេត្តកែប បានប្រជុំចំនួន ២ស្រុក/ក្រុងគឺ ស្រុកដំណាក់ចង្អើរ និងក្រុងកែប
- ខេត្តកោះកុង បានប្រជុំ ចំនួន ៣ ស្រុកគឺ ស្រុកគិរីសាគរ ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល
- ខេត្តព្រះសីហនុ បានប្រជុំចំនួន ៣ស្រុកគឺ ស្រុកកំពង់សីលា ស្រុកព្រៃនប់ និងស្រុកស្ទឹងហាវ។



*រូបភាពទី៦៤៖ សិក្ខាសាលាផ្សព្វផ្សាយ នៅស្រុកកំពង់ត្រាច ខេត្តកំពត*



*រូបភាពទី៦៥៖ សិក្ខាសាលាផ្សព្វផ្សាយនៅស្រុកដំណាក់ចង្អើរ ខេត្តកែប*

## ៦.៦.៣ ការចុះប្រមូលទិន្នន័យ

គម្រោងបានចុះសិក្សា និងប្រមូលព័ត៌មានពីប្រតិបត្តិករចំនួន ១២ស្ថានីយនៅក្នុងខេត្តកំពត ខេត្តកោះកុង និងខេត្តព្រះសីហនុ ស្តីពីលទ្ធភាព និងសមត្ថភាពក្នុងការផ្គត់ផ្គង់ទឹកស្អាត ការពង្រីកបណ្តាញ ផែនការអាជីវកម្ម បញ្ហាប្រឈម និងចំណាប់អារម្មណ៍ក្នុងការចូលរួមជាមួយគម្រោង។

## ៦.៦.៤ ការសិក្សាសមិទ្ធិលទ្ធភាព

គម្រោងបានសិក្សាសមិទ្ធិលទ្ធភាពស្តីពី «**ស្ថានភាពការប្រើប្រាស់ទឹកស្អាត និងស្វែងរកវិធីសាស្ត្រក្នុងការផ្តល់សេវាទឹកស្អាតជូនប្រជាពលរដ្ឋ**» ក្នុងស្រុកគោលដៅទាំង ១០ស្រុក (៤៧ឃុំ)។ តាមការសិក្សានេះបានបង្ហាញថាវិធីសាស្ត្រក្នុងការផ្តល់សេវាទឹកស្អាតជូនប្រជាពលរដ្ឋ រួមមាន៖

- ការឧបត្ថម្ភធនលើការបណ្តាញទឹកស្អាតដោយសហការជាមួយប្រតិបត្តិករដែលកំពុងប្រតិបត្តិការនៅក្នុងតំបន់ទាំងនោះ
- ការបង្កើតទឹកសហគមន៍នៅតំបន់ដាច់ស្រយាលដែលពុំមានអាជ្ញាបណ្ណពីក្រសួងឧវបន

- ការបង្កើតស្ថានីយផលិតទឹកផឹក ( ទឹកធុង២០លីត្រ )
- ការដំឡើងអាងចម្រោះខ្សាច់ ( Bio-sand water filter )
- ដឹកស្រះសហគមន៍។



*រូបភាពទី៦៦៖ កិច្ចពិភាក្សាក្រុមរបស់សិក្ខាកាមនៅស្រុកស្រែអំបិល*

# ៦.៧. គម្រោងឧបត្ថម្ភធនលើថ្លៃភ្ជាប់ទឹកជូនគ្រួសារក្រីក្រ ( EMW )

## ៦.៧.១ ការឧបត្ថម្ភធនលើថ្លៃភ្ជាប់ទឹកជូនគ្រួសារក្រីក្រ

សមាគមបានអនុវត្តគម្រោងឧបត្ថម្ភធនលើថ្លៃភ្ជាប់ទឹកសម្រាប់គ្រួសារក្រីក្រក្នុងឆ្នាំ២០២០ ដែលមានស្ថានីយទឹកស្អាតចំនួន ១៧ស្ថានីយបានចូលរួមអនុវត្តគម្រោង។ ជាលទ្ធផលប្រជាពលរដ្ឋដែលមានប័ណ្ណសមធម៌ (ក្រកម្រិត ១ និងក្រកម្រិត ២ ) ចំនួន **២,៩៧០ខ្នងផ្ទះ** បានភ្ជាប់ទឹកស្អាតប្រើប្រាស់។

*តារាងទី៣៖ បញ្ជីឈ្មោះប្រតិបត្តិករដែលទទួលការឧបត្ថម្ភធនលើថ្លៃភ្ជាប់ទឹកជូនគ្រួសារក្រីក្រ*

| ល.រ | ឈ្មោះប្រតិបត្តិករ | #គ្រួសារក្រីក្រដែលបានភ្ជាប់ទឹកស្អាត |
|---|---|---|
| ១ | ស្ថានីយផ្គង់ផ្គង់ទឹកស្អាត កំចាយមារ | ៧០០ |
| ២ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ចំការលើ | ៣៥១ |
| ៣ | ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ម៉ារីន ពេជសារ | ២៣៥ |
| ៤ | ស្ថានីយផ្គង់ផ្គង់ទឹកស្អាត ក្រូចឆ្មារ | ១៨៦ |
| ៥ | ស្ថានីយផ្គង់ផ្គង់ទឹកស្អាត ជ្រោយបន្ទាយ | ១៣៦ |
| ៦ | ស្ថានីយផ្គង់ផ្គង់ទឹកស្អាត ត្បែងខ្ពស់ | ១២០ |
| ៧ | ស្ថានីយផ្គង់ផ្គង់ទឹកស្អាត ក្រុងដូនកែវ | ២៧៦ |
| ៨ | ស្ថានីយផ្គង់ផ្គង់ទឹកស្អាត ពង្រមហាលាភ | ៥២ |
| ៩ | ស្ថានីយផ្គង់ផ្គង់ទឹកស្អាត ឃុំសំរោង | ៥៥ |
| ១០ | ស្ថានីយផ្គង់ផ្គង់ទឹកស្អាត គ្រាង ស្រីពេជ្រ | ១៥៧ |
| ១១ | ស្ថានីយផ្គង់ផ្គង់ទឹកស្អាត ភ្នំហាន់ជ័យ | ៧៤ |
| ១២ | ស្ថានីយផ្គង់ផ្គង់ទឹកស្អាត កោះមិត្ត | ៥ |

| ល.រ | ឈ្មោះប្រតិបត្តិករ | #គ្រួសារក្រីក្រដែលបានភ្ជាប់ទឹកស្អាត |
|---|---|---|
| ១៣ | ស្ថានីយផ្គង់ផ្គង់ទឹកស្អាត អូរតាប៉ោង | ៨៦ |
| ១៤ | ស្ថានីយផ្គង់ផ្គង់ទឹកស្អាត និទាន | ៦៨ |
| ១៥ | ស្ថានីយផ្គង់ផ្គង់ទឹកស្អាត ម៉ី មាន | ៧៧ |
| ១៦ | ស្ថានីយផ្គង់ផ្គង់ទឹកស្អាត ផារ័ត្ន វឌ្ឍនៈ | ២០៩ |
| ១៧ | ស្ថានីយផ្គង់ផ្គង់ទឹកស្អាត ឃុំមៀន | ១៨៣ |
| | **សរុប** | **២,៩៧០តំណ** |

### ៦.៧.២ ការផ្តល់រង្វាន់លើកទឹកចិត្តសម្រាប់ប្រតិបត្តិករឆ្នើម

គម្រោងបានជ្រើសរើសប្រតិបត្តិករឆ្នើមចំនួន ៣ស្ថានីយ ដែលខិតខំប្រឹងប្រែងក្នុងការតភ្ជាប់បណ្តាញជូនគ្រួសារក្រីក្រ និងការអនុវត្តគម្រោងបានល្អ រួមមាន៖

- ជ័យលាភីលេខ១ បានទៅលើស្ថានីយផ្គត់ផ្គង់ទឹកស្អាត កំចាយមារ
- ជ័យលាភីលេខ២ បានទៅលើស្ថានីយផ្គត់ផ្គង់ទឹកស្អាត ចំការលើ និង
- ជ័យលាភីលេខ៣ បានទៅលើស្ថានីយផ្គត់ផ្គង់ទឹកស្អាត ម៉ារីន ពេជសារ។



*រូបភាពទី៦៧៖ ការផ្តល់រង្វាន់ជ័យលាភីជូនប្រតិបត្តិករឆ្នើម*

## ៦.៨ គម្រោងសិក្សារៀបចំព័ត៌មានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសម្រាប់អេកទុនកម្ចី- Water.org

### ៦.៨១. កិច្ចប្រជុំពិភាក្សាអំពីការប្រមូលទិន្នន័យ

សមាគមបានសហការជាមួយក្រុមហ៊ុន អ៊ី.ផៅវ័រ ស៊ី ស៊ី អិល ឯ.ក រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពី«**ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត**» ក្រោមអធិបតីភាព **ឯកឧត្តម រស់ សាលី** អនុរដ្ឋលេខាធិការ ក្រសួងឧវបន។ សិក្ខាសាលានេះមានអ្នកចូលរួមសរុប ៥៥នាក់ (ស្រី ២០នាក់)។



*រូបភាពទី៦៨៖ រូបថតអនុស្សាវរីយ៍ក្រោយបញ្ចប់សិក្ខាសាលានៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២*

### ៦.៨.២ កិច្ចប្រជុំពិភាក្សាអំពីការប្រមូលទិន្នន័យ

សមាគមបានសម្របសម្រួលកិច្ចប្រជុំពិភាក្សាអំពីការប្រមូលទិន្នន័យសម្រាប់«ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត» ចំនួនពីរលើក៖

- លើកទី១៖ នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២២ មានប្រតិបត្តិករចូលរួមសរុបចំនួន ១០ស្ថានីយ តាមកម្មវិធី Zoom អនឡាញ។
- លើកទី២៖ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ ប្រតិបត្តិករចូលរួមសរុបចំនួន ៧ស្ថានីយ នៅការិ-ល័យសមាគម។



*រូបភាពទី៦៩៖ កិច្ចប្រជុំផ្សព្វផ្សាយគម្រោងដល់អាជីវករផ្គត់ផ្គត់ទឹកស្អាត នៅការិយាល័យសមាគម*

## ៦.៩ កម្មវិធីវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i)

ក្រោមកិច្ចសហការរបស់កម្មវិធីវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ(3i) សមាគមបានរៀបចំសិក្ខាសាលាស្តីពី «**ការបង្ហាញពីផែនទីអន្តរកម្ម PIP សម្រាប់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត**» ចំនួន ៤លើកដូចខាងក្រោម៖

- ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២ នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ សម្រាប់ខេត្តព្រៃវែង តាកែវ ស្វាយរៀង កណ្តាល និងរាជធានីភ្នំពេញ។ សិក្ខាសាលាមានអ្នកចូលរួមសរុបចំនួន ៥៣នាក់ (ស្រី១០នាក់)។
- ថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ នៅសណ្ឋាគារឆ្នេរថ្មី ខេត្តព្រះសីហនុ សម្រាប់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតមកពីខេត្តកំពង់ស្ពឺ កែប កំពត កោះកុង និងព្រះសីហនុ។ សិក្ខាសាលាមានអ្នកចូលរួមចំនួនសរុប ២៧នាក់ (ស្រី ៧នាក់) មកពី ១១ស្ថានីយ និងតំណាងមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ និងមីក្រូហិរញ្ញវត្ថុ ISC។

- ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ នៅសណ្ឋាគារ លី ជី ខេត្តក្រចេះ ដែលមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចូលរួមចំនួន ២២ស្ថានីយ មកពីខេត្តកំពង់ចាម ត្បូងឃ្មុំ ក្រចេះ មណ្ឌលគិរី និងប្រជាពលរដ្ឋចូលរួមសរុបទាំងអស់ចំនួន ៤០នាក់ (ស្រី១១នាក់)។
- ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ នៅសណ្ឋាគារ ក្លាស់ស៊ី & ស្ប៉ា ខេត្តបាត់ដំបង ដែលមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចូលរួមចំនួន ២៨នាក់ មកពីខេត្តពោធិ៍សាត់ បាត់ដំបង កំពង់ឆ្នាំង កំពង់ធំ សៀមរាប ព្រះវិហារ ឧត្តរមានជ័យ និងបន្ទាយមានជ័យ សរុបទាំងអស់ចំនួន ៤៣នាក់ (ស្រី៦នាក់)។



*រូបភាពទី៧០៖ ការធ្វើបទបង្ហាញអំពីគម្រោងដោយលោកស្រី ហួត ណារី នៅសណ្ឋាគារក្លាស៊ី ខេត្តបាត់ដំបង*